# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ មាស សុខា អាយុ៤៥ឆ្នាំ ភេទប្រុស

## អ្នកឃ្វាលគោនៅក្នុងគុកក្រាំងតាចាន់

## នៅភូមិស្រែគ្រួ ឃុំដាំងទង ស្រុកត្រាំកក់ ខេត្តតាកែវ

## នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៥

## សម្ភាសន៍ដោយៈ ញាណ សុជាតិ និង គង់ សុកគឿន

## សរុបៈ ៥៣ទំព័រ

ខៈ សម័យឥលូវហ្នឹង?

ខៈ សម័យឥលូវហ្នឹង រឿងឈឺចាប់ក៏ខ្ញុំវា កន្លងហួសយូរហើយ ខ្ញុំវាកាត់បន្ថយបន្តិចរឿងឈឺចាប់ វាឈឺចាប់ហើយ ប៉ុន្តែវាធ្វើម៉េច កាលកន្លងហួស ខ្ញុំវាថយចុះនឹងការ ឈឺចាប់ហើយ ។

ខៈ ប៉ុន្តែខ្ញុំគ្រាន់តែចង់អោយក្រុមរាជរដ្ឋាភិបាល ហើយហ្នឹងអង្គការសហប្រជាជាតិ ជួយកាត់ក្តី រកយុត្តិធម៌អោយត្រឹមត្រូវ ។

ខៈ ហ្នឹងហើយ តើហេតុអ្វីបានជាគេសម្លាប់ខ្មែរអាហ្នឹង ចង់ដឹងតែប៉ុណ្ណឹង ។

ខៈ ហ្នឹងហើយ សម័យខ្មែរ ហេតុអីបានជាខ្មែរ មិនគិតខ្មែរ ឈាមខ្មែរ បាននាំគ្នាសម្លាប់មនុស្សយ៉ាងវេទ្ធាល ដីព្រៃផ្សៃ ។

ខៈ មាស សុខា ។

ខៈ ហ្នឹងហើយ ។

ខៈ ៤៥ ។

ខៈ កើតជានៅហ្នឹងតែម្តង ។

ខៈ ភូមិហ្នឹង ។

ខៈ ភូមិស្រែគ្រួ ហ្នឹងតែម្តង ។

ខៈ ឃុំដាំងទង ។

ខៈ	ពីឆ្នាំ១៩៧៦ គេយកឪពុកខ្ញុំទៅ គេយកម្តាយ ហើយនិងខ្ញុំហ្នឹង ទៅតាមក្រោយគេដាក់ឡានយកទៅ ដាក់នៅក្នុងអគ្គរកាមួយយប់ ដល់តែមកដល់ហ្នឹង គេបញ្ជូនទៅក្រាំងតាចាន់ហ្នឹងតែម្តង ដល់តែបញ្ជូនទៅក្រាំងតាចាន់ ខ្ញុំក៏មិនដឹងអីដែរ គិតតែតូច យើងវាប៉ុន្នានយល់ដឹង កាលជាប់គុកអី បើខ្ញុំមិនដែលស្គាល់គុកឯណា ។

ជាតិៈ	ពូរៀបការកាលពីឆ្នាំណាដែរ?

ខៈ	ខ្ញុំ ១៩៩៤ ។

ជាតិៈ	អូ! ១៩៩៤នេះហើយអេ?

ខៈ	បាទ! ១៩៨៤ ។

ខៈ	២៤ដែរហ្នឹង ។

ជាតិៈ	ហើយពូកាលពីសង្គមលន់ នល់មានបានរៀនសូត្រទេ?

ខៈ	ខ្ញុំអត់ទេ ។

ខៈ	ក្រោយខ្មែរក្រហម ខ្ញុំធ្វើទាហាន ។

ជាតិៈ	ចូលធ្វើទាហានកាលពីអង្កាល់?

ខៈ	នែ ១៩៧៩ ។

ខៈ	ចាំ ខេត្តតាកែវតែម្តង ។

ជាតិៈ	វាយដល់ណាខ្លះ?

ខៈ	វាតែខេត្តកំពត ខេត្តអីហ្នឹង ។

ខៈ	ហើយការឈប់ធ្វើទាហ៊ានទៅ ដល់តែឆ្នាំ ១៩៨៧ ឈប់ ។

ខៈ	ខ្ញុំពិការភ្នែក ។

ខៈ	បាទ! ភ្នែកខ្ញុំពិការតាំងពីអាយុ១២ ។

ខៈ	ស្តាំ ខ្ញុំមើលអត់ឃើញទេ ។

ខៈ	មើលអត់ដឹងទេ មួយភ្នែត ។

ខៈ	ទេ ខ្ញុំមិនដឹងដែរ ព្រោះកាលខ្ញុំពីតូច ខ្ញុំប៉ុននេះ ព្រោះឪពុកខ្ញុំថាភ្នែកឈឺហើយ កាលហ្នឹងខ្ញុំដឹងខ្លួនរហូត ពីព្រោះមូស វត្តព្រុយអេ ហើយត្រូវកែងភ្នែកឈឺរហូតកាលហ្នឹង ។

ខៈ	កូនចៅខ្ញុំបីនាក់ ។

ខៈ	អត់មានស្រី មានប្រុសទាំងអស់ ។

ខៈ	ហើយខ្ញុំជំនាន់ប៉ុល ពតហ្នឹង គេអោយឃ្វាលតែក្របីទេ ។

ខៈ	កាលនៅក្នុងភូមិ ក៏គេអោយឃ្វាលគោដែរ នៅតាមសហករណ៍ ឃ្វាលគោ ។

ខៈ	កើតឆ្នាំ ៦០ ។

ខៈ	ដឹង វាព្រៀង លន់ នល់ វាយជាមួយខ្មែរក្រហម ខ្មែរក្រហម វាយជាមួយលន់ នល់ ទំលាក់គ្រាប់បែក គ្រាប់ផ្លោង គេចគ្រាប់ផ្លោង វឹវក់ដូចគ្នាហ្នឹង វាយយកទាហាន លន់ នល់ ចងមុខតាមផ្លូវមកហ្នឹង ។

ខៈ	ខ្ញុំអត់ដឹងទេ រឿងរដ្ឋប្រហារនោះ ដំបូង ខ្ញុំមិនដែលដឹងទេ ។

ខៈ	មុនខ្មែរក្រហម ខ្ញុំទើបតែអាយុ៩ឆ្នាំហ្នឹង ។

ខៈ	ថ្នាក់ទី ១០ តែឥលូវគេថា ថ្នាក់ទី១ ។

ខៈ	ក្រោយឆ្នាំ១៩៧០ ។

ខៈ	១៩៧០ដាង ។

ខៈ	មានអីមិនដឹង ។

ខៈ	វាយនៅអង្គតាសោម វាយនៅស្វាយព្រៃ តាកែវហ្នឹង ភ្នំពេញហ្នឹង ។

ខៈ	អត់ទេ ភូមិខ្ញុំបរិសុទ្ធ តែគ្រាប់ផ្លោងមួយ ចូលអត់ចុះ ។

ខៈ	មិនដឹងបារមីយ៉ាំងម៉េច ខ្ញុំអត់ដឹងដែរ ព្រោះគោលដៅគេ គេទំលាក់គ្រាប់បែកនៅក្នុងភូមិ ខ្ញុំតែធ្លាក់ហួសហ្នឹងទៀត ។

ខៈ	បាទ! នៃ១៧នេះ ។

ខៈ	ឆ្នាំ ១៩៧០ ។

ខៈ	ហ្នឹងហើយ ។

ខៈ	សកម្មភាពដំបូង វាស្ងួតបូតទេ រឿងខ្មែរក្រហម បើត្រឹម ទើបពីសាហាវត្រឹមឆ្នាំ១៩៧៥ -១៩៧៦ ហ្នឹងតើពីដំបូងមានអី ។

ខៈ	ស្ងួតហ្នឹង វារឿងប្រមូលផ្តុំកំលាំង សាមគ្គីគ្នា វាយ លន់ នល់ វាយអាមេរិកាំង ។

ខៈ	ហ្នឹងហើយ ដល់តែអញ្ចឹង ប្រមូលកំលាំងគ្នា ម៉េចនឹងវាយនេះបាន អាមេរិកាំង ជាមួយ លន់ នល់កើត ។

ខាៈ ខ្ញុំដែល ។

ខាៈ ប៉ុន្តែ គ្រាន់តែឆាប់ត្រឡប់មកវិញ ។

ខាៈ ឆ្នាំ១៩៧៤ អើ មុន១៩៧៥ ។

ខាៈ ខ្ញុំអត់កែនទេ ខ្ញុំទៅខ្លួនខ្ញុំតែម្តង ។

ខាៈ ១៨ឆ្នាំ ។

ខាៈ ទៅឆាប់ទេ កាលហ្នឹងខ្ញុំត្រឡប់មកវិញ កាលហ្នឹងខ្ញុំនៅស៊ើរ ហើយណាមួយម៉ែខ្ញុំ ទៅយកវិញផង គេមិនអោយនៅផង ។

ខាៈ នៅភូមិរំចង់ ។

ខាៈ ហ្នឹងហើយ ។

ខាៈ គេបបួលទៅជាមួយគេទៅ ហើយចុះកាលហ្នឹង មិនបាច់អាណានេះទេ តែគេបបួល គេទៅហើយ ។

ខាៈ ចង់ចូលខាងខ្មែរក្រហម គេរំដោះជាតិ ។

ខាៈ មិនមែនរំដោះហើយ ជុយស្រឡះអញ្ចឹង ។

ខាៈ ខ្ញុំចង់អោយទឹកដីខ្មែរបានសំបូររុងរឿង មិនមែនដើម្បីក្រឡាប់ចាក់ កាប់ឈៀកទៅ កាប់ប្រជាជនឯងអី ។

ខាៈ រឿងសម្តេចឪ ខ្ញុំអត់ដឹងទេ កាលហ្នឹង ។

ខាៈ សុខសប្បាយ ។

ខាៈ ខ្ញុំអត់ដឹងទេ ខ្ញុំដេរុង ។

ខាៈ អោយធ្វើនិរសា ដើរតាមគេ ។

ខាៈ កាន់ ។

ខាៈ បាទ ។

ខាៈ កាំភ្លើង កាបីនអូសអី ។

ជាតិៈ ស្តាយយកតែម្តងអេ?

ខាៈ ហ្នឹងហើយ ។

ខាៈ អឺ អត់ទេ ទាល់តែធ្វើសង្គ្រាមពីក្រោយ ១៩៧៩ នេះតែម្តង ខ្ញុំអត់ដែលបាញ់បាន ។

ខ៖ ចូល ប៉ុន្តែខ្ញុំអត់មានប៉ះ ជីវិត ។

ខ៖ រឿងប៉ះជីវិតគេវាស្រួលទេអាហ្នឹង តែបើយើងមិនប៉ះគេ គេក៏មិនប៉ះយើងដែរ ។

ខ៖ ខ្ញុំអត់គិតរឿងជីវិតគេទេ បើថាធ្វើអីក៏ដោយ សព្វថ្ងៃក៏ដោយ ខ្ញុំអត់ប៉ះគេទេ ។

ខ៖ ខ្ញុំសមរភូមិ អន្លង់ក្រៀវ ដីររមៀល ។

ខ៖ វត្តចក ប៉ុណ្ណឹងឯង ។

ខ៖ តែណាបានបាញ់មុន អាហ្នឹងឈ្នះហើយ ។

ខ៖ នៅអន្គតាសោមខ្ញុំអត់ដែលទេ ។

ខ៖ បាទ ។

ខ៖ បី បួន ខែដែរហ្នឹង ។

ខ៖ គេអោយមកវិញដែរណា កាលហ្នឹងខ្ញុំឈឺជងអីជង ។

ខ៖ ពាក់កណ្ដាលហើយ ។

ខ៖ បាទ ។

ខ៖ នៅទេ ។

ខ៖ គេថាខ្ញុំស៊ើរ ។

ខ៖ បាទ! ពិបាក គេថា ពិបាកប្រើឯង ។

ខ៖ គេមេឃុំកាលហ្នឹង ខ្ញុំភ្លេចឈ្មោះហើយ ស្លាប់បាត់ហើយ ហើយណាមួយ មាខាងម្ដាយខ្ញុំ គាត់អត់ចង់ គាត់ធ្វើមេកងដែរ គាត់ថា ចាំអញយកឯងទៅ ។

ខ៖ ហ្នឹងហើយ ។

ខ៖ គាត់យកទៅជាមួយ គាត់ជួបខ្ញុំ ឯងទៅផ្ទះសិនទៅ ចាំអញយកទៅ នៅជាមួយអញស្រួល ។

ខ៖ អត់ ។

ខ៖ បាទ ។

ខ៖ គេមិនអោយមកទេ ពីព្រោះពេលកំពុងសង្គ្រាមអញ្ចឹង ។

ខ៖ ស្នាក់នៅរំចង់ ។

ខ៖ ហ្នឹងហើយ ។

ខៈ បីនាក់១ ។

ខៈ វត់សំបុត្រ ។

ខៈ មកភូមិនេះ ។

ខៈ បាទ! ប៉ុន្តែខ្ញុំស៊ីយ ឪពុកខ្ញុំគេយកទៅសម្លាប់ឆ្នាំ១៩៧៦ហ្នឹង ខ្ញុំអត់ដឹងអីទេ គេយកទៅដាក់គុកហ្នឹងខ្ញុំមិនដឹងទេ ព្រោះវាអត់ដែលស្គាល់គុក គេអោយតែឃ្វាលក្របីហ្នឹង ស៊ីខ្ចង ស៊ីខ្មៅ ស៊ីថ្ងៃន ស៊ីបន្លយ ស៊ីក្អាត់ មើមព្រះ គ្រប់ ស្បែកគោស្អុយៗ អាផ្អែកអន្លាមហ្នឹងយកមកដុតស៊ីទៅ ។

ខៈ នៅផ្ទះ គេអោយឃ្វាលគោ ។

ខៈ បាទ!

ខៈ គោរួម ។

ខៈ បាទ!

ខៈ ដាក់ហើយ ។

ខៈ បាទ!

ខៈ ១៩៧៤ អីគេដាក់រួមបណ្ដើរៗហើយ គោគេដាក់រួម ពី១៩៧៤ហើយ ។

ខៈ ដាក់រួម តាំងពីបាន ពីឆ្នាំង ទូទៅទាំងអស់ អោយតែរបស់នៅក្នុង យើងមានទាំងគោទាំងជ្រូកអី មាន់ទាអី ដំណាំអីក៏ដោយ របស់រួមទាំងអស់ ។

ខៈ ហ្នឹងហើយហូបរួមហើយ ។

ខៈ ១៩៧៤ គេរួមមួយសារ ។

ខៈ មកដល់គេរំសាយវិញមួយសារ ដឹងទេ?

ខៈ អូនឯងអត់ដឹងទេ ហ្នឹងគេរំសាយមួយសារ ។

ខៈ គេរួម មុនដំបូងគេរួមបានមួយខែ ។

ខៈ មួយខែហើយបានរដ្ឋាភិបាលគេ គិតយ៉ាងម៉េចគេថា រំលាយចេញ គេរំលាយចេញ បានទៅដល់ឆ្នាំ១៩៧៥ បែកភ្នំពេញ ហ្នឹងគេចាប់រួមទៀតហើយ ។

ខៈ ហ្នឹងហើយ ។

ខៈ អត់ដឹង ខ្ញុំអត់ដឹងទេ ។

ខា:	ហ្នឹងហើយ ។

ខា:	រឿងថារួម របស់រួមមិនដែលថាស្រួលទេ ។

ខា:	គោម៉ែខ្ញុំមានច្រើនដែរហ្នឹង ។

ខា:	ហ្នឹងហើយ ខ្ញុំមិនភ្លេចទេ រឿងគោ គោម៉ែខ្ញុំច្រើន ។

ខា:	ម្ដាយខ្ញុំរកស៊ី គាត់មានធ្វើអី រឿងឪពុកខ្ញុំគាត់ ។

ខា:	មុន១៩៧៥ហ្នឹង ។

ខា:	ម៉ែខ្ញុំធ្វើជាមួយគេ គេអោយធ្វើអីយើងធ្វើហ្នឹងទៅ ។

ខា:	គឹម ញ៉ូ ។

ខា:	ឪពុក មាស គុន ។

ខា:	មុនខ្មែរក្រហម គាត់រកស៊ីជួញគោគាត់រកស៊ី ។

ខា:	ជួញគោ ហើយដាំដំណាំអាំ ។

ខា:	ហ្នឹងហើយ ។

ខា:	ទល់ដល់ពេល គេយកទៅជាមួយគ្នានៅក្រាំងតាចាន់ហ្នឹង ។

ជាតិ:	អូ រហូតដល់ពេលគេយកទៅអេ?

ខា:	បាទ ។

ខា:	គោប្រហែល៧០គោ គ្នាបីនាក់ ។

ខា:	បាទ ។

ជាតិ:	៧០គោ?

ខា:	បាទ ។

ជាតិ:	ដែលបាត់គោ បាត់អីទេ?

ខា:	អត់ទេ ។

គឿន:	កាលហ្នឹង គេយកពូទៅក្រាំងតាចាន់ពេលណា?

ខា:	បាទ?

គឿន:	គេយកពូទៅក្រាំងតាចាន់ឆ្នាំណា?

ខា:	ឆ្នាំ១៩៧៦ ខែ៦ ។

ខាៈ អាយុ១៦ ។

ខាៈ ១៦ ។

ជាតិៈ ហើយពូមានដឹងថា គេជម្លៀសប្រជាជនមកពីភ្នំពេញទេ ថ្ងៃ១៧ មេសា?

ខាៈ អឺ មិនដឹង ។

ខាៈ កាលហ្នឹងវាអត់ធ្វើអីកាលហ្នឹង វាបែក១៩៧៥ គេអត់មានអោយប្រជាជន ណាទៅធ្វើអីឯណាទេ ចាំទទួលតែម្ដង ។

ខាៈ ហ្នឹងហើយ ។

ជាតិៈ ហើយគេមានបង្រៀនអោយអ្នក អ្នកមូលដ្ឋានហ្នឹង អោយស្អប់អ្នក១៧ទេ?

ខាៈ មាន ។

ខាៈ ថាកុំបាច់មករក មកសួរ ស្វាគមន៍អីវាទេ ។

ខាៈ បាទ ។

ខាៈ គេចាប់ទុកថាជាខ្មាំងអញ្ចឹងទៅណា ។

ខាៈ ហើយចុះបើគេប្រាប់អញ្ចឹងហើយ ខ្ញុំទៅចបែស រឹងរូស ជាមួយគេធ្វើអី ។

ខាៈ អត់ស្វាគមន៍ទេ ។

ខាៈ តាមផ្ទះគេ ដល់នេះ ដល់មកអស់អញ្ចឹង មេកង មេឃុំគេចាត់ចែងអោយទៅនៅ កងនេះ កងនោះអញ្ចឹងទៅ ។

ខាៈ កន្លែងត្រៀម កន្លែងផ្ញើរ កន្លែងពួកកម្លាំងសេះ កម្លាំង ទន់ខ្សោយអីអញ្ចឹងទៅណា ។

ខាៈ មួយអាទិត្យ ។

ខាៈ ហ្នឹងហើយ ។

ខាៈ ហើយចុះគ្នា គេមកដល់គេរាក់ទាក់ហើយ ហើយយើងចេះតែរាក់ទាក់ទៅ ហើយដល់តែហើយអញ្ចឹង យើងនេះទៅណា ។

ខាៈ ក្រោយ នៅតែគ្នាលគោដដែល ។

ខាៈ បាទ ។

ខាៈ ពេលព្រឹកយើងលែងទៅ ដល់ពេលបាយពេលថ្ងៃ យើងដេញគោមក ហើយយើងទៅវិញ ទៀតទៅ ។

ឱៈ ដល់ខែស្រូវគេមានកន្លែងអោយមើលហ្នឹង ។

ឱៈ ហ្នឹងហើយ គេមិនមែនអោយមើលផាកន្លែងស្រូវហ្នឹង គេចេះតែអោយមើលឯណា ។

ឱៈ ពូ គេចាប់ពូទៅ ក្រាំងតាចាន់ហ្នឹង ឆ្នាំណាខែប៉ុន្មាន?

ឱៈ ១៩៧៦ ។

ឱៈ ខែ៦ ។

ឱៈ ទៅដល់ភ្លាម គេដាក់នៅក្នុងផ្ទះ គេដាក់ គេអត់ដាក់ខ្នោះទេ គេដាក់តែម្តាយទេ ។

ឱៈ ច្រើនដែរ មើលម៉ែខ្ញុំ បងខ្ញុំ ប្អូនខ្ញុំ ដូចជាង១០នាក់ ។

ឱៈ បាទ ។

ឱៈ គាត់ទើបតែឆ្លងទន្លេហើយគេអោយវែកអង្ករ ។

ឱៈ បាទ ។

ឱៈ ខែប៉ុន្មាន ខ្ញុំភ្លេចដែរមិនដឹង ខែ៤ អីហ្នឹង ។

ឱៈ ហ្នឹងហើយ ។

ឱៈ គាត់បោះក្បាលកិន ។

ឱៈ បោះត្បាល់កិន ។

ឱៈ ត្បាល់កិន កិនស្រូវហ្នឹង ។

ឱៈ ហ្នឹងហើយ ។

ឱៈ ហ្នឹងខ្ញុំនៅឃ្វាលគោព្រៃ ខ្ញុំមកដល់នេះ ខ្ញុំអត់មានទាន់នរណាប្រាប់ទេ ស្មើហ្នឹង ខ្ញុំទៅមើលគោបាត់ហើយ ។

ឱៈ ដល់តែនេះខ្ញុំ ស្រាប់តែនេះអី ខ្ញុំមក មកខ្លួនឯងទេណា ខ្ញុំមក គេកំពុងតែប្រមូលម៉ែហ្នឹងទៅ គេឃើញខ្ញុំ គេហៅខ្ញុំទៅជាមួយដាក់ឡានទៅជាមួយ ទៅណា ។

ឱៈ ទៅណា ទៅណា ខ្ញុំអត់ដឹង ខ្ញុំអត់មានសួរទេ ដឹងតែអារម្មណ៍តែភ័យ ។

ឱៈ អញ្ចឹង ផ្លូវទៅ អង្គរកាហ្នឹង ផ្លូវអូនឯងជិះឡានមកហ្នឹង ។

ឱៈ ម៉ោងប្រហែល៣ ៣ រសៀល ដល់អង្គរកា គេដាក់ដេកនៅហ្នឹងមួយយប់ ។

ឱៈ ហ្នឹងហើយ ។

ឱៈ ហើយចុះបើគេ មិនទាន់អោយទៅដល់ ។

ខ:	ស្នាក់នៅអាផ្ទះមួយ ត្រង់អញ្ចេះ ផ្ទះនៅ ។

ខ:	មិនមែនទេ អង្គុជ្យារ អង្គុរការនេះ ។

ខ:	ជ្យារតែម្តង ជ្យារ តែម្តងពីដើម ។

ខ:	ដាក់អោយនៅហ្នឹង មួយយប់ ។

ខ:	អ្នកជ្រេងយើងម៉េចហ្នឹងដឹង គេដាក់ មិនមែនអោយយើងឃើញឯណា ។

ខ:	មួយគ្រួសារមួយនាក់ មានរឿងប៉ុន្មាន ប្រមូលដាក់ទៅជាមួយគ្នាទាំងអស់ ។

ខ:	ហ្នឹង ។

ខ:	ឡានអាស៊ីប ។

ខ:	កាត់ កាត់ចិន ។

ខ:	អស់នៅក្នុងភូមិហ្នឹងតែម្តង គេយកទៅទាំងអស់ ប៉ុន្មាននាក់ហ្នឹង ជាង១០នាក់ហ្នឹង ។

ខ:	គ្រួសារពូ ១០នាក់អញ្ចឹង ។

ខ:	ហ្នឹងហើយ ដោយឡែកតែឪពុកខ្ញុំ ហើយបងថ្លៃ ខ្ញុំយកទៅមុន ។

ខ:	យកទៅមុនពីរ ។

ខ:	យកទៅមុនគ្នា ពីរថ្ងៃហ្នឹង ។

ខ:	បាទ ។

ខ:	ខ្ញុំកាលហ្នឹង ខ្ញុំអត់ចាប់អារម្មណ៍រឿងវាយមេ ព្រោះកាលហ្នឹងខ្ញុំគ្រាន់តែលឺ ឪពុកខ្ញុំគាត់និយាយ ។

ខ:	ពេលគាត់ថា គាត់មកពីប្រជុំវិញ អញខ្លាចគេវាយអញនៅនឹងគល់ឫស្សីទេ គាត់លឺខ្លួនគាត់ ទិញតែប៉ុណ្ណឹង ។

ខ:	ខ្ញុំខ្លាចតែគេវាយនឹងគល់ឫស្សីទេ អញខ្លាចតែប៉ុណ្ណឹង ។

ខ:	ហ្នឹងហើយ យកប្រពន្ធកូន ។

ខ:	ហ្នឹងហើយ ។

ខ:	ម្តាយហើយនឹងកូនចៅបងប្អូន អ្នកជាប់និន្នាការជាមួយគ្នា ហ្នឹងទៅ គេយកទៅទាំងអស់ ។

ខ:	អត់ទេ ។

ខ:	អត់ឃើញ គ្រាន់តែឃើញភស្តុតាង ។

ខ: រឿងរស់ រឿងស្លាប់ពេលហ្នឹង គេអត់អោយយើងឃើញទេណា ។

ខ: គេដាក់ផ្ទះខ្ញុំដោយខ្លួន ឪពុកខ្ញុំគេដាក់ផ្ទះដោយខ្លួនហើយ ។

ខ: ពេលសម្លាប់គេយក ចេញដោយខ្លួនហើយ ។

ខ: គេសួរតែចាស់ ចាស់ទេ ក្មេង ក្មេង គេអស់សួរទេ ។

ខ: កាលពីមុនហ្នឹង គេអត់ទាន់អោយធ្វើអី គេដាក់រយៈ អោយមួយខែ ។

ខ: ហ្នឹងហើយ ជាប់នៅនឹងផ្ទះហ្នឹង ។

ខ: អត់ដាក់ខ្នោះទេ ។

ខ: នៅក្នុងហ្នឹងមានធ្វើអី នៅតែអង្គុយតែក្នុងហ្នឹង តូចតាចអី នៅតែអង្គុយតែក្នុងហ្នឹងទៅ ។

ខ: ហ្នឹងហើយ ។

ខ: ដល់មួយខែ បានគេប្រលែងចេញ បានរយៈបីបួន ប្រាំថ្ងៃ ខ្ញុំរាងរឹងជើង រឹងដៃ បន្តិច គេអោយ បបរអោយអីស៊ីអញ្ចឹងទៅ រាង មានកំលាំងបន្តិចគេអោយចាប់ផ្តើមមើលគោ ។

ខ: ហ្នឹងហើយ មើលគោហើយ ហើយដល់តែនេះ បានគេបញ្ជូរអោយមើលក្របី ។

ខ: មេ ។

ខ: គាអាន់ គាពេញអីហ្នឹង ។

ខ: បាទ ។

ខ: គោគេមានតិចទេ ក្របីក៏តិចដែរ មានបួន ។

ខ: ក្របីមានបួនដែរហ្នឹង ។

ខ: គោផ្សេងនោះ ក្របីមួយផ្សេងនោះ ។

ខ: គោបួនដែរហ្នឹង ក្របីបួនដែរ ។

ខ: តែបងខ្ញុំមួយ ហើយប្អូនខ្ញុំស្លាប់ឥលូវ ស្លាប់ពីឆ្នាំមុនហ្នឹងមួយ ហ្នឹងវាមើលគោ ខ្ញុំមើល ក្របី ។

ខ: ហើយអាតូច អស់នេះមានធ្វើអីវា ។

ខ: វាដើរលេងនោះ ។

ខ: ខ្ញុំពីមុនដំបូង គេអោយធ្វើកន្ទេលធ្វើអីអញ្ចឹងទៅ ។

ខ: ហ្នឹងហើយ នៅក្នុងរបងគេ ប៉ុន្តែមិនមែននៅក្នុងផ្ទះទេណា បរិវេណដីគេហ្នឹង គេអោយដើរត្រឹមប៉ុន្នាន យើងដើរត្រឹមហ្នឹងទៅណា ប៉ុន្តែត្រង់ក្មេង អោយឃ្វាលគោមិនអោយឃ្វាលនៅក្នុងហ្នឹងទេ ។

ក: ឃ្វាលនៅក្រៅរបងទៅណា ។

ខ: បាទ ។

ក: គេអត់កំណត់ទេ ។

ខ: ហ្នឹងហើយ ។

ក: ពេលធ្វើកន្ទេលហើយ គេអោយចប់ពីការងាររកន្ទេលហ្នឹង គេអោយជួយរែកដីគេអញ្ចឹងទៅ ជួយដកស្ទូងគេអញ្ចឹងទៅ ខែវស្សាខែអីហ្នឹង ។

ខ: មានស្រែគេរាប់ហិចតាណា ។

ក: មានស្រីមានប្រុស មានខ្លាក់មានខ្វិនអីទាំងអស់ ។

ខ: ហ្នឹងហើយ ដាក់លាយគ្នាហ្នឹង ។

ក: លាយដង្ហែគ្នាហ្នឹង ។

ខ: អត់បាច់ទេ មកបន្ទប់ បន្ទប់គ្នា ដាក់បន្ត បន្តគ្នាហ្នឹង នៅក្នុងមួយគុក មួយគេដាក់មនុស្សទៅ៧០នាក់-៥០នាក់ ។

ក: អត់ទេ ហើយបានគេយកសួរចំលើយហើយ បានគេយកទៅដាក់គុកផ្សេងទៀត ។

ខ: ហ្នឹងហើយ ។

ក: ហ្នឹងហើយ ។

ខ: ដកពីនេះច្រើនទៅដាក់៤-១០-២០នាក់-៣០នាក់អញ្ចឹងទៅ យកពីគុកច្រើនហ្នឹងយកទៅដាក់នោះទៀតទៅណា ។

ក: ខ្ញុំអត់ដឹងរឿងកំហុស ខ្ញុំអត់ដឹង ព្រោះគេនៅស្រុកដោយខ្លួន ភូមិដោយខ្លួន ស្លាប់តែនិយាយរួមហ្នឹង រឿងហើយ ចោទតែខ្មាំងហ្នឹង ឆ្លល់ថានិយាយតែរឿងខ្មាំងមួយម៉ាត់មិនដឹងរឿងអីខ្មាំង បាក់នង្គ័លមួយក៏ខ្មាំង បែកចានមួយក៏ខ្មាំង ដកដំឡូងមួយក៏ខ្មាំង ។

ខ: ថីមិនឃើញ ។

ក: មួយដង ១០-២០នាក់អញ្ចឹង ហើយមកច្រើនតែយប់ ។

ខាៈ មៅ៉ង៩យប់អីហ្នឹង ។

ខាៈ ខ្ញុំអីមិនឃើញ បើខ្ញុំគេដាក់អោយនៅក្រៅ គេមានអោយចូលនៅក្នុងគុកឯណាយប់ឡើង ។

ខាៈ ក្មេង គេអត់អោយចូលដេកទេ គេអោយដេកក្រៅជិតគេណា គេស្រុកហៅទៅឆ្នុះអី កាន់ទ្រង់ កាន់អីគេអញ្ចឹង ។

ខាៈ រាល់យប់ ។

ខាៈ ដប់នាក់ ម្ភៃនាក់ ។

ខាៈ បីនាក់ពីរនាក់អី ។

ខាៈ កាន់កាំភ្លើង ។

ខាៈ ចងខ្សែ ។

ខាៈ អត់បិទទេ ។

ខាៈ នាំចូល គេបើកទ្វារគុកហ្នឹង ចូលទៅ ទៅស្រាយចំណងទៅ ក្រៅទៅ ។

ខាៈ រាល់តែថ្ងៃ អត់មានថ្ងៃខាន តិចបំផុត មួយយប់ មានត្រឹម៥នាក់ហ្នឹងតិចបំផុតណា ។

ខាៈ អីមិនឃើញ ។

ខាៈ ពេលគេសម្លាប់ ភាគច្រើនសម្លាប់មៅ៉ង៧រសៀល ។

ខាៈ ហើយមុននឹងគេសម្លាប់គេចាក់មេក្រូ ឬក៏ចាក់ម៉ាញ៉ៅ គោះជញ្ជាំងអាណា ចេះតែគោះទូងទាំងទៅ ។

ខាៈ គេ អត់ទេ ក្មេងៗអញ្ចឹង គេដេញអោយទៅក្រៅ ។

ខាៈ ដេញអោយទៅក្រៅរបង អោយដើរមើលគោ មើលអីទៅណា ។

ខាៈ ហ្នឹងហើយ ។

ជាតិៈ ហើយចុះមុននឹងគេសម្លាប់គេចាក់មេក្រូ គោះជញ្ជាំង គោះអីអញ្ចឹងទៅ?

ខាៈ ហ្នឹងហើយ ។

គៀនៈ ហើយចុះយ៉ាងម៉េចបានពូដឹងថាគេសម្លាប់?

ខាៈ ហើយចុះអីមិនដឹង បើទំលាប់ឃើញអញ្ចឹងហើយ ។

ខាៈ មើលទីមួយតាអាន់, តាឌុច, ទីបី តាពេញ, ទីបួន តាចេង, ទី៥ តាមឿន, ទី៦ តាអួក ទី៧ ឌុច តួច, ទី៩ សាំង ។

ខ: ទី៨ សារ៉ាំង, ទី៩ ឈឿន, ទី១០ ទូច, ទី១១ ស៊ាន់, ទី១២ ស៊ីម,

ខ: ហ្នឹងហើយ១៣នាក់ អ្នក,

ខ: រាប់ម៉េចទេ,

ខ: បាទ,

ខ: បើក្មេង គេបោកនឹងគល់ឈើ,

ខ: បាទ! បើចាស់អញ្ចឹងដូនណាគេវាយនឹងខ្នង អន្ទើយអីអញ្ចឹងទៅ ហើយគេចាក់នឹង ។

ខ: ហ្នឹងហើយ ដូនណាអា-ក ក អញ្ចឹងទៅ ។

ខ: គេយកម៉ែឪទៅ ជាមួយ គ្នាអញ្ចឹងទៅណា ។

គឿន: អូ ។

ខ: ម៉ែឪ ។

ខ: ទៅដែរ ។

ខ: យកទៅជាមួយគ្នា ។

ខ: គ្មានថ្ងៃខាន ។

ខ: ចូលរាល់ថ្ងៃ ដល់តែណែនមនុស្ស អស់រយៈកុមារ ទំរាំតែអូនឯងចូលអូនឯង នៅមាន កំលាំង គេអត់ទាន់នេះទេ គេនៅសួរចម្លើយហើយ គេនៅទុកនឹងអត់បាយហ្នឹងសិនហើយ គេអោយបបរមួយវែកគ្រលោមទេ អោយហូបហើយ មួយវែកគ្រលោម ហ្នឹងមិនមែន បបរសុទ្ធទេណា មានដំឡូងមី ប៉ិនមេដើងពីរដុំ ។

ខ: ហើយសម្លដើមចេក ដើមអីហ្នឹង គេដាក់ញ៉ាំទៅ ។

ខ: ដល់តែស្គមបន្តិច គេ បញ្ជូនអោយទៅសហករណ៍នេះ សហករណ៍នោះហើយណា ។

ខ: ហ្នឹងហើយ ។

ខ: មានត្រឹមតិចបំផុត ១០នាក់ ។

ខ: ១០០នាក់ចុះ ។

ខ: ហ្នឹងហើយ ។

ខ: ១២ហ្នឹង បើអ្នកណាមានមុខការងារគេ គេទៅក្រៅបាត់ គេទៅបាត់ទៅ អ្នកនៅហ្នឹង យើងធ្វើការទៅ ។

ខាៈ អត់ចង់ទេ ជិតដល់ ជួនណាខ្លះគេចង់ដែរ ។

ខាៈ បាទ ។

ខាៈ ខ្លះអត់ចង់ទេ ។

ខាៈ អត់ចង់ទេ គេរត់អត់រួចទេ រួចម៉េច បើស្គមនៅតែក្បាលជន្លង់ហើយ រត់យ៉ាងច្រើន បានតែត្រឹមជុំថ្មនេះ ។

ខាៈ គេមិនយកទៅមួយដង ១០០ទេ គេយកមួយដង២ ។

ខាៈ បាទ ។

ខាៈ បញ្ជូនទៅតាម តាមក្រោយ ក្រោយនេះ អូនឯងបុគ្គលិកអញ្ចឹង នាំមួយដង ពីរ មួយដងពីរទៅ អ្នកនៅសម្លាប់នោះ ចេះតែសម្លាប់ទៅ អ្នកនៅចាំសម្លាប់នោះ ហើយខ្ញុំអ្នកនៅចាំរណ្ដៅ ចេះតែថាធាក់ ធាក់ កាប់ ។

ជាតិៈ អញ្ចឹង អាកន្លែង យកមួយរយហើយ មិនមែនទៅដល់កន្លែងរណ្ដៅភ្លាមទេអេ?

ខាៈ អត់ទេ ។

ខាៈ ហ្នឹងហើយ ។

ជាតិៈ អ្នកណាគេ អ្នកយកទៅដាក់រណ្ដៅ សម្លាប់អីខ្លះ?

ខាៈ សម្លាប់អីខ្លះយ៉ាងម៉េច សម្លាប់មនុស្សហ្នឹង ។

ជាតិៈ សម្លាប់មនុស្សហ្នឹងនរណាគេខ្លះ?

ខាៈ បុគ្គលិកគេហ្នឹង ។

ជាតិៈ ស្មើដៃគ្នាទាំងអស់អេ?

ខាៈ ហ្នឹងហើយ ស្មើគ្នា ។

គៀនៈ ហើយចុះពូ ដូចថាពេលសម្លាប់ច្រើន អញ្ចឹង ។

ខាៈ ហ្នឹងហើយ ។

គៀនៈ ១២ នាក់ គេមានដែលអ្នកទោស ដូចគ្នាសម្លាប់ទេ?

ខាៈ គេប្រើដែរហ្នឹង ។

គៀនៈ ញឹកញាប់ទេ?

ខាៈ អត់ទេ ។

ជាតិៈ ហើយចុះគេដែលប្រើពូទេ?

ខាៈ អត់ទេ ក្មេងៗគេមិនប្រើ ចាស់ក៏គេមិនប្រើដែរ មិនសំខាន់គេអត់ប្រើទេ សំខាន់ដៃឆ្វេង នៅក្នុងទូកហ្នឹង មានតែ តាសែនហ្នឹងមួយទេ អាចជាទំនុកទុកចិត្តអីបាន។

គឿនៈ បាទ ហើយចុះម៉េចគេទុកចិត្តគាត់?

ខាៈ ព្រោះនៅហ្នឹងយូរហើយ ហ្នឹងហើយរឿងជាប់នៅណា។

គឿនៈ ១៩៧៤មក?

ខាៈ ហ្នឹងហើយរឿងជាប់ពីណា ឆ្នាំប៉ុន្មាន អីប៉ុន្មាន ខ្ញុំអត់ដែលសួរទេ សែនហ្នឹង។

ជាតិៈ បាទ តែទុកចិត្តគាត់ដែរនែ?

ខាៈ ហ្នឹងហើយ សែនដើរទៅដល់ណា ក៏ចេះតែដើរទៅ សែនហ្នឹង ដើរឆ្ងាយឯណា ក៏ចេះតែ ដើរទៅ។

ជាតិៈ អញ្ចឹងនិស្សិត ដើរគាត់មានសិទ្ធិដែរ?

ខាៈ ដើរគ្នាឯណា ក៏ចេះតែដើរទៅ ប៉ុន្តែអោយចូលវិញ។

គឿនៈ អញ្ចឹង។

ខាៈ ហ្នឹងហើយ។

ជាតិៈ ហើយចុះពូមានដែល គេសម្លាប់ហើយ គេប្រើពូអោយអូសខ្មោច បញ្ជូនទៅកប់អីទេ?

ខាៈ ខ្ញុំគេអត់ប្រើទេ ខ្ញុំនៅក្មេង។

**Side B**

ជាតិៈ គេអោយពុះអុស ខ្មោច មួយដងដែរ ពុះអត់រួច?

ខាៈ ហ្នឹងហើយ។

ជាតិៈ ហើយយកអីអូសអី?

ខាៈ ចាក់កន្ទ្រេង។

ជាតិៈ ចាក់កន្ទ្រេង។

ខាៈ ហ្នឹងហើយ។

ជាតិៈ អូសទៅតែម្តងហើយ អូសតែមួយដងទេអេ?

ខា៖ អូសតែមួយដងទេ ខ្ញុំ ។

គឿន៖ ពេលពូឃើញរណ្តៅ មានឃើញរណ្តៅហ្នឹង ពូមានឃើញរណ្តៅហ្នឹង ឃើញសាកសព ។

ខា៖ សាកសព គេកាយកប់ហើយ គេអត់មានទុកអោយ អោយគេឃើញទេ ។

គឿន៖ ឃើញតែអាមួយពុសអុស ហ្នឹងទេ?

ខា៖ ហ្នឹងហើយ ប៉ុនតែដឹងសុទ្ធតែខ្មោច អត់មានអាណាថាមិនខ្មោចទេ ។

គឿន៖ អូសហ្នឹង សាកសពប្រុស អេសាកសពស្រី?

ខា៖ ប្រុស ។

គឿន៖ អាយុប្រហែលប៉ុន្មាន?

ខា៖ អាយុប្រហែលខ្ទង់ស្រករ ស្រករខ្ញុំដែរ ហើយហ្នឹង ។

ជាតិ៖ ស្លាប់នឹងអី?

ខា៖ វាយពេលសួរចំលើយ វាយទន់ខ្លួន ទន់អី ។

ជាតិ៖ ស្រករពូ ពេលមុន អេពេលពូឥលូវ?

ខា៖ ស្រករប្រហែលខ្ញុំឥលូវហ្នឹង ។

ជាតិ៖ អូ! ចាស់ដែរហើយ ។ ហើយចុះហូបចុកយ៉ាងម៉េចនៅក្នុងគុក?

ខា៖ ហូបចុកវេទនាដំបូង ។

ជាតិ៖ អូ ដំបូង? ហើយចុះក្រោយមកធូរ?

ខា៖ ក្រោយក៏អត់ធូរទេ រឿងយើងជាប់គុក វាពិបាកអា៎ យើងជាប់គុក គេមិនដែលអោយយើងហូបឆ្អែតទេ ។

ជាតិ៖ បាទ ។

ខា៖ គេ អោយយើងមួយត្រឡោកប៉ុណ្ណោះទេនែ មានតាំងពីដំឡូង មានតាំងពីសំឡ ដើមចេកហ្នឹងសំឡដើមចេក មានតែអំបិលទេ អត់មានប្រហុកទេ ។

ជាតិ៖ អ្នកទោសទាំងអស់ហ្នឹង មានពាក់លេខកូដនៅលើខ្លួនទេ?

ខា៖ អត់ទេ មិនគុកសម័យឥលូវទេ គុកនេះដឹងតែយកមនុស្សទៅដល់ដាក់ យកទៅដល់ដាក់សួរចម្លើយៗអត់មានសួររឿងអី សួររឿងចំនុចតែខ្លាំង ឯងស៊ើបការណ៍អោយយួន សេអ៊ី អា អាមេរិកាំង ឯងពាក់សក្តិប៉ុន្មាន តែប៉ុណ្ណឹង ។

គឿនៈ ហើយចុះពូមានដឹងតួនាទីអ្នកណាអ្នកចាំសួរចម្លើយ អ្នកណាអ្នកចាំបញ្ជូនទេ ពូមានដឹងទេ?

ខាៈ តួនាទីនៅក្នុងគុក គេមានតែ អាន់, តាឌុច, តាពេញ, តាចេង បី បួននាក់ ហ្នឹង ។

គឿនៈ បាទ! ហើយអ្នកចាំសួរចម្លើយ ពីណាគេ?

ខាៈ អ្នកសួរចម្លើយ មានតែបីបួននាក់ហ្នឹងហើយ ។

ជាតិៈ តា ពេញ ។

ខាៈ ពេញ, ចេង, ឌុច ។

ជាតិៈ ឌុច ។

ខាៈ ហើយតាអាន់ហ្នឹង ។

ជាតិៈ ឌុច ហ្នឹង ឌុច តូច, អេ ឌុច ធំ?

ខាៈ ឌុច ធំ ។

ជាតិៈ ឌុចធំអេ?

ខាៈ ហ្នឹងហើយ ។

ជាតិៈ ធំ តាអាន់ ៤នាក់ហ្នឹង ។

ខាៈ ហ្នឹងហើយ ។

ជាតិៈ ហើយចុះអ្នកដែលកត់អត្ថលិខេ?

ខាៈ ឌុចតូច ។

ជាតិៈ ឌុចតូច ហើយចុះអ្នកសម្លាប់តែម្តង?

ខាៈ ថា ទូទៅទាំងអស់ ១២នាក់ហ្នឹង ។

ជាតិៈ ហើយចុះអ្នកទៅនាំអ្នកទោសមក?

ខាៈ អ្នកទោសប្តូរគ្នា ។

ជាតិៈ ប្តូរគ្នាទៀត ។

ខាៈ ពេលអូនឯងហត់ទៅ អូនឯងអ្នកនាំទៅ ។

គឿនៈ អូ ហើយចុះពេលដែលទៅយកមកតាមសហករណ៍?

ខាៈ តាមសហករណ៍ ឈ្លប តាមភូមិ តាមឃុំ ។

គឿនៈ គេអ្នកបញ្ជូនមក?

ខា: ហ្នឹងហើយ ។

ជាតិ: អញ្ចឹងវិញនែ ។

ខា: ហ្នឹងហើយ ។

គឿន: ហើយចុះពូ ដូចថាសួរចំលើយហើយអ្នកដែលស៊ីញ៉ៅ អោយសម្ងាប់វិញពីណាគេ?

ខា: ស៊ីញ៉ៅអោយសម្ងាប់ មានតែបុគ្គលិកហ្នឹងតែម្តង ។

ជាតិ: ហើយអ្នក១២នាក់ហ្នឹង ដេកនៅក្នុងគុក អីនៅក្នុងគុកអីទាំងអស់អេ? ដេកនៅឯណាដែរ?

ខា: អត់ទេ គេផ្ទះគេដោយខ្លួន ។

ជាតិ: រាល់ថ្ងៃឯណាបានគេទៅធ្វើការនៅហ្នឹង?

ខា: គេធ្វើការនៅក្នុងហ្នឹងទាំងយប់ទាំងថ្ងៃ ឧបមាបើអ្នកនៅមន្ទីរ កន្លែងបុគ្គលិកគេធ្វើការផ្សេង អញ្ចឹងទៅ គេធ្វើផ្ទះមួយផ្សេង ពីរបីអញ្ចឹងទៅណា ។

ជាតិ: អូ ។

ខា: ពួកគេមានផ្ទះប៉ិនៗហ្នឹង ទ្វារធំៗអញ្ចឹង វែងៗអញ្ចឹងទៅ គេដាក់ក្តារជញ្ជាំង ក្តាររនាប ក្រោមអញ្ចឹង រនាបអញ្ចឹង គេវែងលួសអញ្ចឹង លួសបន្លា ។

ជាតិ: បាទ ។

ខា: ទាំងលើ ទាំងក្រោម ។

គឿន: ហើយចុះពូនៅក្នុងហ្នឹងមានគុកអីខ្លះ ដូចគុកងងឹត គុកអីមានទេ?

ខា: អត់មានទេ ។

ជាតិ: អត់មានគុកងងឹតទេ?

ខា: បាទ! រឿងគុកងងឹត ខ្ញុំអត់ដឹងទេ ។

គឿន: ហើយចុះមានប្រភេទដូចជាគុក សំរាប់ដាក់ម្នាក់ៗដែលគេខ្សែរ៍តចុះទៅអីមានទេ?

ខា: មានដែរ ប៉ុន្តែខ្ញុំអត់ដែលពិនិត្យមើល នៅក្នុងហ្នឹង ។

ជាតិ: អូ!

ខា: គុកខ្ញុំចូល គុកខ្ញុំម្នាក់ឯងហើយហ្នឹង ។

គឿន: ម្នាក់ឯងគេដាក់ខ្សែរ៍តចុះទៅក្រោមអីអញ្ចឹង?

ខា: ហ្នឹងហើយ ព្រោះកន្លែងបែកជ្រុងនេះមួយ គេធ្វើរោងមួយសំរាប់សួរចំលើយ អ្នករីង ។

ជាតិៈ បាទ ។

ខាៈ អ្នកគុកនៅហ្នឹង គេយកទៅដាក់ខ្សែរ៉ែត ខ្សែអីហ្នឹងគេប្រាប់ខ្ញុំតែម្តង ពួកបុគ្គលិកហ្នឹងគេប្រាប់ គេដាក់ ។

ជាតិៈ នរណាគេប្រាប់?

ខាៈ ពួក សីញ, សាុំគេហ្នឹង ។

ជាតិៈ ហើយពូ អត់មានដែល ដឹងឪពុកពូទេ?

ខាៈ អត់ទេ ។

ជាតិៈ មានដឹងឪពុកពូគេសម្លាប់អីអន្លាល?

ខាៈ រឿងសម្លាប់ពីអន្លាលហ្នឹងគេយក ខ្ញុំអត់ដឹងទេ ប៉ុនតែគេអត់ទុកយូរទេ ។

ជាតិៈ អញ្ចឹង ។

ខាៈ យ៉ាងច្រើនកន្លះខែ ។

ជាតិៈ អត់ដឹងថានរណាគេសម្លាប់គេទេនែ?

ខាៈ ប្រហែលបុគ្គលិកគេតែម្តង ។

គឿនៈ បើគេជ្រុលប្រាប់ថា ឪពុកពូទុកនៅកន្លែងហ្នឹងហើយ ពូមានសួរបន្ថែមគេ អ្នកណាគេសម្លាប់ទេ?

ខាៈ អត់ទេ សម្លាប់បង ម្តាយធំ ឪពុកធំហ្នឹង មួយគ្រួសារហ្នឹង យកទៅដាក់នៅហ្នឹងដែរ អស់មួយពូជហើយហ្នឹង ហ្នឹងអស់មួយពូជៗនរណា កូនប៉ុន្មាននាក់ហ្នឹង យកទៅទាំងអស់ហ្នឹង អត់រួចខ្លួនអីមកវិញទេណា ទាំងកូន ទាំងម៉ែ ទាំងឪអី ស្លាប់ទាំងអស់នៅហ្នឹង ។

គឿនៈ ហើយចុះពូក្រោយ ក្រោយមក ពូនៅក្នុងគុកហ្នឹង ពូមានដែលធ្លាប់ឃើញបងប្អូនពូអីជាប់សាច់ញាតិជាមួយពូអី គេទៅក្រោយៗៗអី ធ្លាប់ស្គាល់ទេ ឬក៏អ្នកនៅក្នុងភូមិជាមួយពូ?

ខាៈ ខ្ញុំគ្រាន់តែ អត់មានជាប់សាច់ញាតិទេ អ្នកជាប់ក្រោយៗគ្រាន់តែស្គាល់ មនុស្សពីស្រុកយើងទៅ ដូចជាវិស្សុករ នៅភូមិសន្ទរ វិស្សុករ រៀននៅបារាំង ។

គឿនៈ ពូមានដែលស្គាល់គាត់អញ្ចឹង មានដែលទៅនិយាយជាមួយគាត់ទេ ពេលឃើញគាត់ចូល?

ខាៈ គេមិនអោយនិយាយទេ គេមិនអោយមើលមុខគ្នាផង រឿងអោយទាក់ទងគ្នា មិនទេ ។

ជាតិៈ បាទ ។

ខា៖ ធ្វើម៉េច ដាច់ខាតទៅ ឧបមាថាឪពុកគេអោយកូនសម្លាប់ៗបាន ត្រូវតែសម្លាប់ ចាំបាច់រើសថាគេអោយទៅសម្លាប់ខ្មាំងទេ មិនអោយទៅសម្លាប់អីទេសំខាន់បំផុតខ្មាំងសេ អ៊ី អា អាមេរិកាំង ហើយសេ អ៊ី អា យួនហ្នឹងតែម្ដង គេនិយាយតែប៉ុណ្ណឹង ។

ជាតិ៖ ហើយចុះអ្នកដែលធ្វើការនៅក្នុងគុកហ្នឹងមានដែលនិយាយគំរាមពូចង់សម្លាប់ពូទេ?

ខា៖ គេគ្រាន់តែគំរាមទៅ គំរាម វាយ អីអញ្ចឹងដែរ ។

ជាតិ៖ យកអីវាយ?

ខា៖ យករំពាត់តូចតាច ថាយើងមើលក្របី កុំអោយបេះតែបាត់បេះតែអីអញ្ចឹងទៅណា វាយ វាខែប្រាំង វាអត់ទឹក អត់ស្មៅហ្នឹង វារើ វាមិនដាច់ ក្របីឈ្មោល វាមិនរើទេ ទាញចុះទាញឡើង វាខឹងនៅត្រង់ហ្នឹង គេយករនាស់អី វាយពីរ បី ថ្ពក់អញ្ចឹងទៅ ថាឯងមើលគក់ក្របីចេញ ថាមើលម៉េច បើខ្ញុំ ក្របីចង បើអោយខ្ញុំចង បើអោយលែងវាមានអីខ្ជិលដើររក ដើរអីគេដែរហ្នឹង ។

គឿន៖ កាលហ្នឹងគេអោយពូ ដើរទៅមើលដល់ណាខ្លះពូ?

ខា៖ មានមើលដល់ណាៗ គេនិយាយអោយតែក្របីឆ្អែត ឯងមើលដល់ណាក៏ដោយអោយតែដល់ផ្ទះវិញ ។

គឿន៖ ពូធ្លាប់ទៅដល់ណាខ្លះដែរ?

ខា៖ អត់ឆ្ងាយប៉ុន្មានទេ ខ្ជិលដើរដែរ ដើរអីឆ្ងាយម៉េះ កន្លែងណាក៏ដោយអោយតែមានស្មៅ ។

ជាតិ៖ ហើយចុះពូថា បាត់គោ បាត់ក្របីអី ទៅដើររកអី ហើយគេចាប់បានយ៉ាងម៉េច?

ខា៖ ខ្ញុំបាត់ក្របី ដល់តែបាត់ក្របី គេដើរ ដើររក ដើររកអញ្ចឹង ឈ្លបគេ ចាប់បន្តអញ្ចឹងគេយកទៅដាក់ឃុំគោទៀត ។

ជាតិ៖ ឃុំជាមួយគោ?

ខា៖ ហ្នឹងហើយ ។

ជាតិ៖ ហើយគេថាម៉េចទៀត បានគេលែងវិញ?

ខា៖ ហើយចុះពួកបុគ្គលិកវាធ្លាប់ឃើញខ្ញុំនៅហ្នឹងហើយ វាមិនដឹង ពួកអ្នកដែលមេឈ្លបហ្នឹងថាឯងមកអី ខ្ញុំបាត់ក្របី ក្របីឯងទៅឆ្ងាយនៅឯណាចុះ ប៉ុន្តែគេដឹងហើយ ព្រោះបុគ្គលិកគេ ជិះដើររក គេចូលប្រាប់ហើយ ហើយហ្នឹងហើយ ។

ជាតិៈ ហើយចុះគេប្រាប់ថាម៉េច?

ខាៈ គេមិនដឹងប្រាប់ថាម៉េច ប៉ុនគេដឹងថា ខ្ញុំបាត់ក្របី ដើររកក្របី ប៉ុនតែគេនាំចូល អ្នកនាំហ្នឹង វាអត់ស្គាល់ខ្ញុំទេ វាមិនដែលចូលនៅក្នុងហ្នឹង គេមិនមែនចេះតែអោយចូលផ្ដេសផ្ដាសទេកន្លែងគុកហ្នឹង តែចូលទៅសុទ្ធតែជាប់នៅក្នុងហ្នឹងហើយ បើមិនដែលដឹងចូលទៅកុមារអូនឯង ខបមាថាផ្លូវហ្នឹង ឃើញដើរទក់ ទក់ ចេះតែឃើញគេជិះកង់នឹងព្រៃ ឃើញជិះកង់នឹងព្រៃកាត់ គេឃាត់ព្រឹក អត់មានទុកទេ យ៉ាងច្រើនតែប្រាំថ្ងៃ គេសម្លាប់ចោលបាត់ហើយ ។

ជាតិៈ បាទ ។

ខាៈ ចូលទៅ ដល់តែអ្នកហ្នឹងស្គាល់ជិតដឹតខ្លាំងណាស់ បានអាចអោយចូលបាន អ្នកហ្នឹងចូលហើយ បន្តិចថាអោយចេញ មកនិយាយរឿងអី អ្នកឯងក៏ស្លាប់ដែរ អត់មានទុកទេ ។

គឿនៈ ហើយចុះពូទៅរកក្របី គេចាប់ឃុំប៉ុន្មានម៉ោង ប៉ុន្មានថ្ងៃ បានគេប្រលែងអោយមកវិញ?

ខាៈ អត់ឃុំប៉ុន្មានថ្ងៃផង គេអោយហូបបាយហើយ គេអោយមកវិញ ។

ជាតិៈ ហើយចុះពូ នៅក្នុងគុកហ្នឹងនៅ ពូមានដែលធ្លាប់ឃើញអ្នកថ្នាក់ដឹកនាំធំៗ គេទៅទស្សនៈកិច្ច នៅកន្លែងគុកហ្នឹងទេ?

ខាៈ ដែល ដែល ។

គឿនៈ អ្នកណាគេខ្លះពូ?

ខាៈ ត្រឹមថ្នាក់ស្រុកទេ ថ្នាក់ស្រុក ថ្នាក់តំបន់ ។

ជាតិៈ នរណាគេហ្នឹង?

ខាៈ ខ្ញុំអត់ស្គាល់ទេ ខ្ញុំលឺត្រឹមចៅហ្វាយខេត្តហ្នឹង ។

ជាតិៈ នរណាគេចៅហ្វាយខេត្ត?

ខាៈ គិត ។

ជាតិៈ គិត ។

ខាៈ អឺ ។

គឿនៈ ហើយចុះថ្នាក់ស្រុក ថ្នាក់តំបន់នរណាគេ?

ខាៈ ថ្នាក់ស្រុក កាលហ្នឹង តាជឹម ។

ជាតិៈ តាជឹម ។

ខាៈ តាជឹមនៅភូមិភាគ ខត្តរមួយ ឌុចធំនេះ ឌុចធំហ្នឹង ផ្លាស់ទៅភូមិភាគខត្តរ ។

គឿនៈ បាទ! ហើយនរណាទៀតខស្សាហ៍មកកន្លែងហ្នឹង? តាម៉ុក មានដែលមកទេ?

ខាៈ តាម៉ុក អត់ដែលទេ គេមក ក៏ខ្ញុំអត់ស្គាល់គេដែរ ។

គឿនៈ មានឃើញឡាន ឃើញអី គេជិះមកទេ?

ខាៈ អត់ឡាន អត់មានផ្លូវឡានទេ ។

ជាតិៈ ហើយចុះពូពេលដែលគេមកហ្នឹង គេមកត្រឹមបារ៉ូ អ្នកធ្វើនៅក្នុងហ្នឹងឬក៏គេមកមើលអ្នកទោស ដែរ?

ខាៈ គេអត់មើលទេ អ្នកទោស ។

គឿនៈ គេមកនិយាយគ្នា ពួកធំៗដែរ?

ខាៈ ហ្នឹងហើយ រឿងហ្នឹងវែងឆ្ងាយអូន បើនិយាយទៅ វានាំតែ សៅហ្មង ។

ជាតិៈ អេ អត់អីទេ មានរឿងអីត្រូវសៅហ្មង ។

ខាៈ ហ្នឹងហើយ ។

ជាតិៈ រឿងហ្នឹង វាកន្លងទៅយូរហើយ ។

ខាៈ ប្រវត្តិជួរចត់ វាមិនមែនស្រួលអី ។

ជាតិៈ ឥលូវពូនិយាយអោយអស់មើល ចង់និយាយអីខ្លះ?

ខាៈ ខ្ញុំវា អស់យោបល់និយាយ ។

ជាតិៈ ពូនៅ៣-៤ឆ្នាំ និយាយប៉ុនហ្នឹង ម៉េចទាន់អស់ពូ និយាយពីដើមរហូតមកដល់ចប់មើល?

ខាៈ និយាយពីដើមរហូតមកដល់ចប់ឯណាទៀត ។

ជាតិៈ អានៅក្នុងគុកហ្នឹងមើល ។

ខាៈ នៅក្នុងគុកហ្នឹង មានអី គ្រាន់តែគេអោយខ្ញុំមើលក្របី ។

ជាតិៈ មានដែលធ្វើអីខុសទេ មានដែលធ្វើអោយក្របី ឈឺ ក្របីអីទេ?

ខាៈ ធ្វើក្របី ឈឺវាដែល ដែលហ្នឹង ។

ជាតិៈ គេមានដាក់ពូទេ?

ខាៈ គេអត់ដាក់ទោសទេហ្នឹង ព្រោះគេដឹងក្របីឈឺ គ្រប់កន្លែងហើយគេអោយបុគ្គលិក គេធ្វើម្ហូបធ្វើអីទៅណា ហើយយើងអ្នកទោស អ្នកអីហ្នឹង ធ្វើស៊ីខ្លះទៅណា ។

ជាតិៈ អញ្ចឹង ។

ខាៈ ហ្នឹង គេអោយតែសាច់ក្បាលសាច់អីអញ្ចឹងទៅ សាច់ឆ្អឹងជំនី ឆ្អឹងអីទៅណា ស៊ីមិនអោយបោះចោលទេ ទុកគ្រាន់អ្នកទោសស៊ីអញ្ចឹងទៅ ប៉ុនតែស៊ីបានតែពួកឃ្វាលដែរទេ អ្នកនៅក្រៅហ្នឹង ប៉ុនតែអ្នកជាប់នៅក្នុងគុកហ្នឹង គេអោយទៅស៊ីសម្ល‌ចេក ដើមចេក ដើមព្រលឹតហ្នឹងអីហ្នឹងទេ ស្លមមាន ។

ជាតិៈ ដែលជួបពូសែនទេ?

ខាៈ បាទ.?

ជាតិៈ ដែលជួបពូសែន?

ខាៈ ពូសែន នៅតែជាមួយគ្នាហ្នឹង ចេញចូល គេឡើងត្នោត ខ្ញុំឃ្វាលក្របីទៅ ។

ជាតិៈ ដែលនិយាយរកគ្នាដែរតើអី?

ខាៈ ជឺ មិនដែលនិយាយ មានអីរឿងពួកនៅជាប់អញ្ចឹង លែងអីហើយ ពួកនៅក្រៅ ទាក់ទងគ្នាបានតើ ដោយឡែកតែពួកនៅជាប់ហ្នឹង នៅក្នុងគុកហ្នឹងយើងមិនអាច ទៅនៅក្នុងគុកបានទេ ។

ជាតិៈ ហើយអ្នកនៅក្នុងគុកហ្នឹង ថ្ងៃឡើងគេអត់អោយបញ្ចេញទៅធ្វើការទេ?

ខាៈ ជួនណា ខែស្ទូងអញ្ចឹង គេបញ្ចេញ អោយជួយស្ទូង ត្រឡប់ពីស្ទូងមកវិញអញ្ចឹងទៅ ថ្ងៃក្រោយប្រហែលបី បួនថ្ងៃ អីអញ្ចឹង គេយកទៅ សម្លាប់ចោល ។

ជាតិៈ អូ សម្លាប់ចោល ពេលយកទៅសម្លាប់ ចាក់មេក្រូអញ្ចឹងតែម្ដងអេ?

ខាៈ ចាក់មេក្រូ វាយធុង បើកធុងបាស ធុងអីអញ្ចឹង ។

ជាតិៈ អញ្ចឹងចាក់ភ្លេងទៀត?

ខាៈ ហ្នឹងហើយ កុំអោយយើងលឺ ។

គឿនៈ ពូនិយាយពី រៀបរាប់ពីទ្រង់ទ្រាយរបស់គុកហ្នឹង វាមានប្រហែលប៉ុន្មាន ហើយគេធ្វើរបងវាមេ៉ច ហើយវាមានទ្វារប៉ុន្មានអីប៉ុន្មានពូ?

ខាៈ ទ្វារមានតែមួយ ។

គៀនៈ ទ្វាមានមួយ ទ្វារចូល ។

ខាៈ ហ្នឹងហើយ ដល់តែរបងវាមានទ្វារលិចទ្វារកើត របងខាងក្រៅ ខ្ញុំអត់និយាយពីក្នុងផ្ទះ នៅក្នុងផ្ទះមានតែមួយទេ ។

គៀនៈ អាទាំងអស់តែម្ដង អាឃុំ?

ខាៈ អាឃុំ បរិវេណ ដីហ្នឹង ។

គៀនៈ បាទ ។

ខាៈ មានពីរ មានបី ។

គៀនៈ ខាងណាខ្លះ?

ខាៈ ខាងលិច ខាងជើងអីមានគ្រប់ច្រក ។

គៀនៈ គ្រប់ច្រក ។

ខាៈ ហ្នឹងហើយ ។

គៀនៈ ហើយគេខស្សាប់នាំមនុស្សចូលទិសខាងណា?

ខាៈ ទិសខាងលិច ទិសខាងកើត ។

គៀនៈ ទិសខាងលិច ទិសខាងកើត ។

ខាៈ បាទ ។

គៀនៈ ហើយចុះខាងជើង ខាងត្បូងគេទុកធ្វើអី?

ខាៈ ខាងជើង ខាងត្បូងគេចំហបោល យើងឥវ៉ាន់យើងទៅមើលក្របី យើងចេះចេញតាមហ្នឹងទៅណា ។

គៀនៈ ហើយដីប្រហែលប៉ុន្មានហិចតាដែរ?

ខាៈ ដី ខ្ទង់ពីរហិចតាជាង ។

គៀនៈ ពីរហិចតាជាង ។

ខាៈ ហ្នឹងហើយ ។

គៀនៈ ហើយមេក្រូហ្នឹង គេដាក់ប៉ុន្មានទិស?

ខាៈ ដាក់មួយទិស ដាក់កន្លែងសម្ងាប់ គេមិនអោយ និយាយរួមមិនអោយអាអ្នកនៅក្នុងគុកហ្នឹងវាលឺ ។

គៀនៈ បាទ

ខាៈ ចាក់រេករហឹងអញ្ចឹងទៅ គេមិនអោយអ្នកនៅក្នុងគុកលីទេ

ជាតិៈ ហើយមុនហ្នឹងបញ្ចេញអ្នកទោសចេញពីគុកទៅសម្លាប់គេប្រាប់អ្នកទោស ថាយ៉ាងម៉េចដែរ?

ខាៈ ទៅសហករណ៍ ។

ជាតិៈ ទៅសហករណ៍

ខាៈ ហ្នឹងហើយ អោយវិលត្រឡប់ទៅសហករណ៍វិញ បងប្អូនកុំភ័យកុំគិត កុំបាច់មាត់កអី ទៅដល់វិញ គេសួរថាទៅណាមកណាអីថា យើងទៅរៀនសូត្រអញ្ចឹងទៅណា

ជាតិៈ បាទ ហើយចុះគ្រាន់តែលឺពាក្យថាទៅសហករណ៍អញ្ចឹង អ្នកទោសយ៉ាងម៉េចដែរ សប្បាយចិត្តដែរ?

ខាៈ លឺ សហករណ៍អញ្ចឹង គេសប្បាយចិត្តហើយ ត្រឡប់ទៅវិញហើយ ។

ជាតិៈ មានហោមានអីទេ?

ខាៈ វាមិនហោទេ រឿងហោ អត់ហោទេ ប៉ុនទៅដោយមុខក្រៀមក្រំដែរហ្នឹង ។

គៀនៈ ហើយចុះពូ ពីកន្លែងដែលគេឃុំឃាំងអ្នកទោស ហើយពីកន្លែងដែលសម្លាប់មនុស្ស ឆ្ងាយពីគ្នា រឺក៏ជិតពីគ្នាប្រហែលប៉ុន្មានដែរ?

ខាៈ ដីប្រហែល៥០ម៉ែត្រ ។

គៀនៈ ៥០ម៉ែត្រពីកន្លែងដាក់អ្នកទោស ។

ខាៈ ហ្នឹងហើយ របងគុកហ្នឹងវាពីរជាន់ ហើយរបងក្រៅវាមិនជាន់ របងក្នុងវាមួយជាន់ ។

គៀនៈ របងហ្នឹង គេដាក់ម៉េចពូ ដាក់បន្លា ឬក៏?

ខាៈ ដាក់បន្លាលួស ។

គៀនៈ ដាក់បន្លាលួស ។

ខាៈ ហ្នឹងហើយ គោក្រាក់ ហើយធ្វើរបងមុន របងក្រោយពីរជាន់ ជាន់ក្រោយហ្នឹង ទើបតែធ្វើទេ ធ្វើកាលពីខ្ញុំភ្ជាប់ហ្នឹងហើយ ។

ជាតិៈ ពូមានដែលឃើញអ្នកទោសគេប្រលែងអោយធ្វើស្រែថ្ងៃៗឡើង លួចរត់អី គេបាញ់ទេ?

ខាៈ មានរត់មួយនាក់ ។

ជាតិៈ មួយនាក់ ម៉េចពូរៀបរាប់មើល?

ខាៈ រត់ហ្នឹង ពេលគេ កំពុងសួរចំលើយ ។

ជាតិៈ បាទ ។

ខាៈ ពេលកំពុងសួរចំលើយអញ្ចឹង សួរគេវាយក្តុងក្តាំងៗអញ្ចឹង រត់ៗអញ្ចឹង រត់អត់បានដី ១០០ម៉ែត្រទេ ដួលហើយ ហើយចុះមនុស្សអត់បាយហើយ រត់អីរួច ពីស្រុកពីភូមិហ្នឹងដែរ ភូមិទួលសង្កា ស្រុកភូមិទួលសង្កា ។

ជាតិៈ អញ្ចឹង ។

ខាៈ បាទ ។

ជាតិៈ អញ្ចឹងគេបាញ់ចោលតែម្តង?

ខាៈ គេយកមកគេវាយចង់ងាប់ហើយ មិនបាញ់នាំតែបង្ហិនគ្រាប់ធ្វើអី រឿងបាញ់គេអត់បាញ់ទេ ។

ជាតិៈ អញ្ចឹងគេអត់បាញ់ទេនែ?

ខាៈ រឿងបាញ់អត់ទេ កន្លែងហ្នឹងមិនអាចផ្ទុះអាវុធទេ ។

ជាតិ មានចាប់រំលោភ ចាប់អីទេ?

ខាៈ រឿងចាប់រំលោភ ខ្ញុំអត់ដឹងទេ ។

គឿនៈ ហើយចុះស្រី ហើយប្រុស គេវាយតែកន្លែងតែមួយទេពូ?

ខាៈ កន្លែងតែមួយ អត់មានកន្លែងពីរ បីទេ បារ៉ូ គ្រាន់តែសួរ ចម្លើយ ប៉ុណ្ណឹង ។

គឿនៈ បាទ ។

ខាៈ មកផ្តៅគេប៉ុណ្ណឹង ប៉ុណ្ណឹង ចង្វាក់ ។

គឿនៈ ពូនៅក្នុងគុកហ្នឹង មានឃ្លាំងស្រូវ ឃ្លាំងអីដែរ?

ខាៈ មាន ។

គឿនៈ អាស្រូវដែលធ្វើបានហ្នឹង យកមកដាក់នៅក្នុងហ្នឹង ។

ខាៈ ហ្នឹងហើយ ។

គឿនៈ ហើយកាលហ្នឹងចុងភៅមានប៉ុន្មាននាក់តែម្តាយពូមួយ រឺក៏អ្នកណាគេខ្លះ?

ខាៈ ចុងភៅ ម្ដាយខ្ញុំ តែពេលចុងភៅ ហាណូយ មួយគេសម្លាប់ចោលហ្នឹង គេអោយម៉ែខ្ញុំដាំទៅ ។

គឿនៈ អូ ម្ដាយពូ គេចាប់ផ្ដើមប្រើអោយធ្វើចុងភៅនៅឆ្នាំណាទៅ?

ខាៈ នៅឆ្នាំ១៩៧៧ ។

គឿនៈ ១៩៧៧ ហើយ ។

ខាៈ ព្រោះចុងភៅ ពីដើម គាត់ហាណូយ គេសម្លាប់ចោលហើយណា ។

គឿនៈ ស្រី អេ ប្រុស?

ខាៈ ប្រុស ។

គឿនៈ មកពីហាណូយ?

ខាៈ ហ្នឹងហើយ ។

គឿនៈ កាលហ្នឹងពូ លឺសួរប្រជាជនថា ដូចថាម្ហូបនៅក្នុងគុកហ្នឹង ដូចជាព្រលិតអី ដូចអត់លាងអត់អីអញ្ចឹង ។

ខាៈ អត់លាងទេ ដើមចេកក៏មិនមែនយកដើមចេកក្រមុំដែរ យកអាដើមចេកកាប់ផ្លែហើយហ្នឹង តែម្ដង ។

ជាតិៈ កាប់ផ្លែហើយ ចាស់ ចាស់គ្រីកហើយហ្នឹង ។

ខាៈ ហ្នឹងហើយ ។

គឿនៈ និយាយអញ្ចឹងពូម្ហូបហ្នឹង ម្ដាយពូមានចេតនាធ្វើ រឺក៏គេបញ្ជាអត់អោយលាង?

ខាៈ គេបញ្ជាអោយធ្វើ ចានក៏គេអត់អោយលាងទេ ចាន អាចាន ប្រឡាក់អាចម៍មាន់អីក៏ដោយ មាន់អាចម៍ដាក់ក៏ដោយ ប្រឡាក់ដីក៏ដោយ គេមិនអោយយើងលាងទេ ។

គឿនៈ អោយដួសអោយអ្នកទោសតែម្ដងអេ?

ខាៈ ហ្នឹងហើយ ។

គឿនៈ ពេលហ្នឹងគាត់ដាំបាយហើយ គាត់ អ្នកវាស់អោយគេអេ?

ខាៈ គេកំណត់អោយតែមួយវែកដឹឡូងយើងអា៎ អាវែកដឹឡូងយើង តូចៗហ្នឹង ។

គឿនៈ បាទ ។

ខាៈ មួយវែកៗ ហ្នឹងហើយ ។

គៀនៈ គាត់ដើរកាន់វាល់អោយគេ?

ខាៈ ហ្នឹងហើយ គេដួស ដាក់តំរៀបតុគេមួយអញ្ចឹង ហ្នឹងគេដាក់ចាន តំរៀបអញ្ចឹងដួស ហើយលើកយកហុចអោយគេទៅណា ម៉ែខ្ញុំហ្នឹងណា ។

គៀនៈ កាលហ្នឹងមានចាស់ ចាស់ច្រើនទេពូ?

ខាៈ អត់មានទេ មានតែម្តាយខ្ញុំមួយ ។

គៀនៈ អាយុចាស់ជាងគេ ។

ខាៈ ហ្នឹងហើយ ។

គៀនៈ ហើយដល់តែពេលចែកវាល់អង្ករ វាល់អីហ្នឹង អើ គ្នាប៉ុន្មាននាក់ រឺក៏តែគាត់មួយនាក់ទេ?

ខាៈ ហើយចុះមានទៅនៀយហត់អី ទៅធ្វើដាំស្លអីច្រើន ខ្វះច្រើនឆ្នាំងអី ខ្វះដៃប៉ុណ្ណឹង ហ្នឹងហ្នឹង ប៉ុននេះ ខ្វះហើយ ដំឡូងពីរ-បីគីឡូ គ្រាន់តែដាក់បបរ លាយអោយ គ្រាន់តែកុំអោយវារាវពេកតើ ។

គៀនៈ ពេលហ្នឹង ពូបាយជាមួយពួកអ្នកទោស ឬក៏ពូ បាយផ្សេង?

ខាៈ បាយគេអោយផ្សេងមែន ប៉ុន្តែបបរ ឆ្នាំងតែមួយហ្នឹង ។

គៀនៈ គ្រាន់តែអត់នៅជាមួយគេ ។

ខាៈ ហ្នឹងហើយ កាក ឧបមា ថាបាយដួសអោយអ្នកទោស អស់ទៅ នៅសល់អាបាតក្រោមរាងខាប់ជាងគេបន្តិចអាំណា គេទុកអោយអាហ្នឹង ។

គៀនៈ អ្នកនៅជាមួយនៅក្រៅហ្នឹង មានប៉ុន្មាននាក់?

ខាៈ អី នៅ មានបីបួននាក់ដែរហ្នឹង ។

ជាតិៈ ពូមានស្គាល់ឈ្មោះពីណាគេ មានចាំទេ?

ខាៈ មើល កាលហ្នឹង តាចិន តាចិនស្លាប់ហើយ សែន ហ្នឹង ហើយ អ៊ីរុន រស់នៅដងទង់អាំអាហ្នឹងគាត់មកក្រោយ ហើយអ៊ីហាន ។

គៀនៈ អ៊ីហាន ។

ខាៈ បងខ្ញុំ ហើយប្អូនៗៗខ្ញុំប៉ុន្មាននាក់ហ្នឹង ។

គៀនៈ ប្រហែល១០នាក់ដែរ?

ខា: ប្រហែល១០នាក់ដែរហ្នឹង អត់មានក្រោម១០នាក់ទេ មានតែ១០នាក់ ១២នាក់ អីប៉ុណ្ណឹង ។

គឿនៈ ហើយអាយុប្រហែលប៉ុន្មាន អ៊ី រុន អ៊ី ហានអីហ្នឹង?

ខា: អ៊ីរុនហ្នឹង គាត់២០ជាងហើយ ។

គឿនៈ នៅជាមួយពូ អីនៅក្រៅ នៅសំរាកនៅក្រៅទាំងអស់ទេ?

ខា: ពេលថ្ងៃអញ្ចឹង គេអោយដើរធ្វើការអញ្ចឹង យប់ឡើងគេដាក់នៅក្នុងគុកអាណា ។

គឿនៈ ដូចថ្ងៃឡើង ដូចអ៊ី ស្រី ស្រី នៅក្រៅហ្នឹង គេច្រើនតែប្រើគាត់អោយធ្វើអី?

ខា: ខែរែកដី រែកដីទៅ ខែច្រូតស្រូវ ច្រូតស្រូវទៅ ខែស្ទូង ស្ទូងទៅ ។

គឿនៈ ដល់តែពួកប្រុស ប្រុស ពីអោយដើរមើលក្របី?

ខា: ហ្នឹងហើយ ក្របី មើល ។

គឿនៈ ហើយចុះប្អូនៗៗពូ?

ខា: ប្អូនៗៗខ្ញុំ វានៅតូច វានៅតែជាមួយម៉ែអញ្ចឹងទៅ ជាមួយម៉ែទៅ គាត់មើលផង គាត់បបរអោយគេអញ្ចឹងទៅ ដាំបាយ ដាំអី ហ្នឹង អោយគេអញ្ចឹងទៅណា ។

គឿនៈ បាទ ។

ជាតិៈ ហើយចុះម្ដាយពូ ចុងភៅ អីអញ្ចឹង ហូបអត់ឆ្អែតទេនែ?

ខា: ហើយចុះបបរគេកំណត់ហើយ ១០០នាក់ ក៏១០កំប៉ុង ២០០នាក់ក៏១០កំប៉ុង មានទៅហូបបានឆ្អែត ធ្វើម៉េចទៅកំណត់ របបគេអស់ប៉ុណ្ណឹងហើយហ្នឹង បបរ១០កំប៉ុង ដង្វាល ៣ គីឡូអីអញ្ចឹងទៅ ហើយហូបឆ្អែតដែរ ។

ជាតិៈ ពូនៅក្នុងហ្នឹង មានដែលឃើញ ឈ្លប គុក ឈ្លបអីហ្នឹង វះកូនក្មេងអីទេ?

ខា: វះ ។

ជាតិៈ វះទៀត?

ខា: អត់ដែលឃើញទេ ខ្ញុំ រឿងវះពោះអោះ រឿងវះ រឿងអី ខ្ញុំ អត់ទាន់ដែលឃើញទេ

ជាតិៈ ឃើញតែអាក?

ខា: អា ក ចាក់ ។

ជាតិៈ ឃើញតែម្ដងអេ?

ខា: ឃើញ ឃើញ ។

ជាតិ: ហើយចុះឃើញអញ្ចឹង អ្នកចាក់ហ្នឹង ដឹងថាពូឃើញដែរ?

ខា: វាអីមិនដឹងអី ថាអី វែងឆ្ងាយ វាមានទាំង តែបំបិទមាត់ទៀត ឯងឃើញ ឯងនៅអោយស្ងៀម ឯងបន្តិចដើរនិយាយអញអាក ឯងដែរហើយ ។

ជាតិ: ដែលនិយាយអញ្ចឹងអោយពូទេ?

ខា: ថាគេប្រាប់អញ្ចឹង ឯងឃើញហើយបន្តិចដើរនិយាយ ដើរ ។

គឿន: នរណាគេកាលហ្នឹង?

ខា: ពួកបុគ្គលិកគេហ្នឹង ។

គឿន: អ្នកនិយាយហ្នឹងឈ្មោះអីគេ?

ខា: ពូ ស៊ីម, ពូ សាំន អញ្ចឹង គាត់ចេះតែប្រាប់អញ្ចឹងថា ឯង អញអាណិតឯងទេ អញមិនធ្វើបាបឯងទេ បើក្រៅពីហ្នឹង អញធ្វើបាបឯងឥលូវហ្នឹង ។

ជាតិ: ម៉េចដែរ ក្បាលគោ ក្បាលអីហ្នឹង លំបាកទេ?

ខា: ឃ្វាលគោ វាលំបាក ទេ គោ ៧០ ក្បាលអីវ៉ាន់ ជិនាន់ប៉ុល ពត ។

គឿន: បាទ ។

ខា: គ្នា បីនាក់ អូនឯងក្បាលកើតទេ ។

ជាតិ: អត់ទេ អាពេលនៅក្នុងគុក ក្បាលគោប៉ុន្មាន គោតែបួនអេ?

ខា: គោ នៅក្នុងគុកអេ ខ្ញុំ វាជួបការលំបាកដែរ ។

ជាតិ: លំបាកយ៉ាងម៉េចទៅ?

ខា: ដើរឃ្វាលហើយ ស្រូវអង្ករគេ ពេញ ស៊ីស្រូវគេមិនបាន ហើយវាខ្វះខាតកន្ទែងស្មៅ ។

គឿន: ស៊ីស្រូវទេ?

ខា: អត់ ទេ អត់ហ៊ានទេ រឿងស៊ីស្រូវអង្ករគេ នាំរឿងទៀត ។

ជាតិ: ហើយក្រៅពីក្បាលគោអញ្ចឹងមានធ្វើអីទៀត?

ខា: អត់មានធ្វើអី គេអោយក្បាលគោ ឃ្វាល ក្របីហ្នឹង ។

ជាតិ: មានខ្មែរក្រហមដែលចាប់កំហុសពូទេ? ដែលគេចាប់កំហុសពូទេ?

ខា: គេអត់ចាប់ដែរទេ ។

ជាតិៈ  អត់ដែលធ្វើខុសទេអេ?

ខាៈ  ហ្នឹង ។

ជាតិៈ  ដែលធ្វើខុសទេ?

ខាៈ  ខ្ញុំធ្វើខុស ធ្វើខុសរឿងបាត់ក្របីហ្នឹង ។

ជាតិៈ  អូ បាត់តែម្ដងហ្នឹង ។

ខាៈ  ហ្នឹងហើយ ។

ជាតិៈ  ហើយរកឃើញទេ ក្របី?

ខាៈ  ឃើញ ។

ជាតិៈ  ឃើញម៉ោងប៉ុន្មាន?

ខាៈ  ម៉ោង ៤ល្ងាចហើយ ។

ជាតិៈ  បាត់ពីម៉ោងប៉ុន្មានទៅ.?

ខាៈ  បាត់ពីម៉ោង ២ រសៀល ដល់តែស្អែកឡើង បានដើររក ។

ជាតិៈ  អញ្ចឹង មិនមែនរកថ្ងៃហ្នឹងទេ ដល់តែស្អែកឡើង ម៉ោង៤ បានរកឃើញ?

ខាៈ  ហ្នឹងហើយ ។

ជាតិៈ  អូ បាត់យូរដែរ?

ខាៈ  ហ្នឹងហើយ បាត់មួយយប់មួយថ្ងៃ ។

គៀនៈ  អូ ។

ខាៈ  ឃើញនៅទន្លេនាម ។

ជាតិៈ  នៅឯណាទៅ?

ខាៈ  ទន្លេនាម ។

ជាតិៈ  ខេត្តអីគេ?

ខាៈ  ខេត្តកំពត ។

ជាតិៈ  ហើយចុះដើរបានឆ្ងាយម៉េះ?

ខាៈ  ហើយចុះនៅហ្នឹងមានបឹង ។

ជាតិៈ  ជិះអីទៅទន្លេនាម ពីនេះទៅ?

ខា: អឺ កាលហ្នឹងមានអីជិះ ។

ជាតិ: ដើរ?

ខា: ដើរ ចេះតែដើរទៅ ។

ជាតិ: ពេលវៀតណាមវាយចូល ពូកំពុងតែធ្វើអី?

ខា: ខ្ញុំ កាលវៀតណាម កំពុងតែប្រូត ។

ជាតិ: ប្រូត ។

ខា: ហ្នឹងហើយ ។

ជាតិ: ហើយចុះម៉េចបានអោយប្រូតទៀតហើយ?

ខា: ហើយចុះអាហ្នឹង ខ្ញុំចេញពីគុកវិញហើយ

ជាតិ: ពូ ចេញខែ ប៉ុន្មានដែរ គុក?

ខា: ខែ៨ ឆ្នាំ១៩៧៨ ។

ជាតិ: ខែ៨ ឆ្នាំ១៩៧៨ គេអោយពូ ចេញពីគុក?

ខា: ហ្នឹងហើយ ។

ជាតិ: ចេញទាំងអស់គ្នាអេ?

ខា: ហ្នឹងហើយ ចេញទាំងអស់គ្នា ។

ជាតិ: ម៉េចអញ្ចឹង?

ខា: ទាំងម្តាយ ទាំងខ្ញុំហ្នឹង ។

ជាតិ: ម៉េចបានគេអោយចេញ?

ខា: គេអោយចេញ ខ្ញុំមិនដឹងធ្វើអី ខ្ញុំមិនដឹងដែរ ។

ជាតិ: គេថាម៉េច?

ខា: គេថាអោយវិលត្រឡប់មកផ្ទះវិញ អោយមកសហករណ៍វិញ ចេញមកនៅភូមិតាវៀបហ្នឹង

ជាតិ: ភូមិអីគេ?

ខា: ភូមិតាវៀប ។

ជាតិ: តាវៀប ។

ខា: អឺ ។

ជាតិៈ  ឆ្ងាយពីក្រាំងតាចាន់ប៉ុន្មានគីឡូ?

ខាៈ  ឆ្ងាយ ។

ជាតិៈ  ភូមិអីគេពូ?

ខាៈ  ភូមិតារៀប ឃុំជើងទង ។

ជាតិៈ  ភូមិតារៀប ឃុំជើងទង ។

ខាៈ  ហ្នឹងហើយ ។

ជាតិៈ  ហើយចុះមកនៅភូមិចាស់យ៉ាងម៉េចដែរ?

ខាៈ  គេអត់អោយមក ។

ជាតិៈ  អត់អោយមក ។

ខាៈ  គេអោយនៅត្រៀម ផ្ញើរនៅហ្នឹងសិន ។

ជាតិៈ  អូ អាហ្នឹងគេហៅផ្ញើរ?

ខាៈ  ហ្នឹងហើយ ផ្ញើរ ។

ជាតិៈ  អញ្ចឹងអេ?

ខាៈ  អឺ ។

ជាតិៈ  ហើយចុះក្រោយមកគេអោយពូធ្វើអីទៀត?

ខាៈ  គេអោយខ្ញុំដើរតាមកង ។

ជាតិៈ  ធ្វើអី?

ខាៈ  វែកដី ។

ជាតិៈ  ហើយចុះម្តាយ?

ខាៈ  ម្តាយខ្ញុំគេអោយដាក់បាយជ្រូក ។

ជាតិៈ  ដាក់បាយជ្រូក ។

ខាៈ  ហ្នឹងហើយ ។

ជាតិៈ  ហើយចុះប្អូនៗៗទៀត?

ខាៈ  ប្អូន ខ្ញុំ អាតូច ៗៗពីរនោះ ស្លាប់នៅនោះហើយ ហើយ ។

ជាតិៈ  បាទ ។

ខាៈ នៅមួយអំបាញ់មិញ ហើយមីមួយនៅភ្នំពេញនោះ វាទៅតូច វានៅតាមយាយ យាយ ។

ជាតិៈ បាទ ។

ខាៈ ហើយខ្ញុំគេអោយដើរវែកដី វែកអីតាមកងអញ្ជើងទៅ ដល់តែខែស្នូង ជួយជូនកណ្តាប់ ជូនអី ទៅជួយវែកកណ្តាប់ អញ្ជើងទៅណា ។

គឿនៈ បានពីរខែអេ?

ខាៈ ហ្នឹងហើយ ដល់តែខែច្រូត ច្រូតអញ្ជើងទៅ ។

ជាតិៈ ហើយចុះដល់ពេលខែវៀតណាមវាយចូល ពូ កំពុងធ្វើអី ច្រូត?

ខាៈ ច្រូត ។

ជាតិៈ ច្រូតនៅឯណា?

ខាៈ ច្រូតនៅម្តុំនេះ នៅ ខាងជើង ចំបារ ។

ជាតិៈ ខាងជើង ចំបារអេ?

ខាៈ ហ្នឹងហើយ ។

ជាតិៈ ហើយរត់ទៅណាទៅ វៀតណាមដេញមក?

ខាៈ រត់ទៅ ដល់ខាងលិចឃ្មួន ។

ជាតិៈ បាទ ។

ខាៈ ខាងលិចឃ្មួន ។

ជាតិៈ ខាងលិចឃ្មួន ។

គឿនៈ ខាងលិចឃ្មួន ខេត្តអីគេពូ? តាកែវ?

ខាៈ តាកែវ ឃុំជើងទងដែរហ្នឹង រត់នៅហ្នឹងបានរយៈមួយអាទិត្យ បានត្រឡប់មកវិញ ត្រឡប់មកភូមិរាប សុំគេពីភូមិរាប មកនៅក្បាលអូរនេះវិញ គេអោយមកនៅត្រឹមក្បាលអូរ ។

គឿនៈ កាលហ្នឹង សុំខាងណា ខាងខ្មែរក្រហម ឬក៏ខាង?

ខាៈ ខាងខ្មែរក្រហមហ្នឹង ។

គឿនៈ កាលពីវៀតណាមចូលមក សុំខាងខ្មែរក្រហម ។

ខាៈ ហ្នឹងហើយ កាលហ្នឹងវៀតណាមចូលមានទាន់ដល់ទីឯណា នៅខាងកើតផ្លូវជាតិលេខបី ណោះហ្នឹង នៅនេះ ខាងខ្មែរក្រហមកាន់កាប់ទាំងអស់ហ្នឹង ។

ជាតិៈ បាទ! ហើយដល់អញ្ចឹងនៅអូរហ្នឹង ប៉ុន្មានថ្ងៃបានចូលមកដល់ភូមិ?

ខាៈ បានមួយអាទិត្យ មួយអាទិត្យរត់រហូត ទល់ដល់ ខែ៨ ។

ជាតិៈ ទៅដល់ណាវិញ?

ខាៈ ទៅដល់ពោធិ៍សាត់ បាត់ដំបង ។

ជាតិៈ រត់ទៅឆ្ងាយទៀតណោះ?

ខាៈ ឡើងភ្នំ ។

គឿនៈ កាលហ្នឹងទៅជាមួយម្ដាយនេះ?

ខាៈ ទៅជាមួយម្ដាយមួយសំបុក បងប្អូនខ្ញុំ អត់តែថៃមួយព្រឹកមិញនេះទេ ក្រៅពីហ្នឹងទៅទាំងអស់ ។

ជាតិៈ ទៅទាំងអស់ ។ រត់តាមផ្លូវពូឃើញទិដ្ឋភាពអីដែរ?

ខាៈ ទិដ្ឋភាពគេ កន្លែងនេះ គេសម្លាប់មនុស្សដែរណា ។

ជាតិៈ ឃើញមនុស្សស្លាប់តាមផ្លូវទេ?

ខាៈ សម្លាប់ហើយគេគ ទុកទាំងគំន គំន សុទ្ធតែចាក់សាំងដុតអោះ នៅខេត្ត ។

ជាតិៈ អ្នកណាគេអ្នកចាក់សាំងដុត?

ខាៈ នៅខេត្តពោធិ៍សាត់ ។

ជាតិៈ ខ្មែរក្រហមអ្នកចាក់សាំងដុតអេ?

ខាៈ ហ្នឹងហើយកាលហ្នឹងមានយួនឯណា យួន មានទាន់ចូលប៉ះឯណា ។

ជាតិៈ បាទ ។

គឿនៈ ពូ តាមផ្លូវណា ពេលទៅ ហ្នឹង វាត់ទៅ ទៅរហូត?

ខាៈ ផ្លូវអេ អាភ្នំឱរ៉ាល់នេះ ។

ជាតិៈ អាម៉េចបានពូរត់?

ខាៈ ហើយចុះបើគេបំផុតថា យួនអាក យួន អាដេញ បោះដែកគោល កៀបដើមស្លា អីឯណាដាក់អាំង មួយកំបុតៗ ។

គឿនៈ អញ្ចឹង ។

ខាៈ ហ្នឹងហើយ ។

គឿនៈ ហើយទៅដល់នោះ បានប៉ុន្មានថ្ងៃ បានពូ ត្រឡប់ មកវិញ?

ខាៈ ខែ៨ បានចូលដល់ស្រុក ។

គឿនៈ ត្រឡប់ពីពោធិ៍សាត់វិញ?

ខាៈ ហ្នឹងហើយ ។

គឿនៈ ហើយដល់ពោធិ៍សាត់ហ្នឹង នៅក្នុងភូមិ ឃុំ ស្រុកអី?

ខាៈ ឃុំ បាត់គគីរ ។

គឿនៈ ឃុំអីគេ?

ខាៈ ឃុំ បាត់គគីរ ស្រុកបាកានហើយអាហ្នឹង ។

គឿនៈ ភូមិអីគេ?

ខាៈ ភូមិបាត់គគីរហ្នឹង ។

គឿនៈ ភូមិបាត់ គគីរ ឃុំបាត់គគីរ ស្រុកបាកាន ។

ខាៈ ហ្នឹងហើយ ។

គឿនៈ មូលហេតុអីបានជាពូត្រឡប់មកវិញ គេប្រាប់ថាម៉េច បានពូត្រឡប់មក?

ខាៈ មូលហេតុ គេថា យកពួកនិរតី សម្លាប់ចោល ។

ជាតិៈ អូ ទៅដល់នោះ ប្រជាជននិយាយអញ្ចឹង?

ខាៈ ហ្នឹងហើយ គេអោយសម្លាប់មែនតើ កុំតែបានពួកស្រុកឈូកទេនេះ ភូមិ និយាយ រួម ភូមិ ពួកឈូកវិញទេ ។

ជាតិៈ ម៉េចអញ្ចឹង?

ខាៈ គេដឹងដែនការណ៍ទាន់ នាំគ្នាហោះចេញទាំងយប់ ។

គឿនៈ កាលហ្នឹងវៀតណាមចូលទៅដល់ឥលូវ?

ខាៈ នៅទេ ។

គឿនៈ នៅទេ ប៉ុន្តែ អ្នកដែលនិយាយហ្នឹង ប្រជាជន ឬក៏ខ្មែរក្រហម?

ខាៈ ប្រជាជនតែម្តង គេអ្នកធ្វើការដែរ គេធ្វើការខ្មែរក្រហម ដែរប៉ុនគេដឹង ។

ជាតិៈ អញ្ចឹងអេ?

ខាៈ ហ្នឹងហើយ ។

ជាតិៈ ដឹងហើយធ្វើម៉េចទៀត?

ខាៈ ដឹង គេនាំគ្នាជម្លៀសចេញ ពីហ្នឹងមក ។

ជាតិៈ ជម្លៀសចេញពីហ្នឹងមកតែម្តង?

ខាៈ ហ្នឹងហើយ ។

ជាតិៈ ហើយចុះម៉េចបានខាងហ្នឹង ស្អប់ពួកនិរតីហ្នឹង?

ខាៈ ពួកខាងបូព៌ា ពួកខាងភូមិភាគពាយ័ព្យ គេស្អប់ ភូមិភាគនិរតី ពីព្រោះពួកភាគនិរតី គឺ ពួកតំបន់ មេខ្មែរក្រហម ។

ជាតិៈ អឺ គេស្អប់អញ្ចឹងអេ?

ខាៈ ហ្នឹងហើយ ។

ជាតិៈ ពួកហ្នឹងធ្វើបាបគេអេបានគេស្អប់?

ខាៈ ពួកភូមិភាគនិរតី គេធ្វើបាប ខ្លាំង គេរកមុខ ។

ជាតិៈ ហើយចុះពូ ត្រឡប់មកភូមិវិញខែណា?

ខាៈ ខែ៨ ។

ជាតិៈ ឆ្នាំ១៩៧៩?

ខាៈ ១៩៧៩ ។

ជាតិៈ មកដល់ឃើញអ្នកភូមិហ្នឹងនៅភូមិហ្នឹងអស់ទេ?

ខាៈ នៅខ្លះអត់ខ្លះ ។

គឿនៈ ពេលដែលពូត្រឡប់មក វៀបត្រឡប់មកហ្នឹង វៀតណាមនៅនេះទេ?

ខាៈ មកហើយ ។

គឿនៈ មកហើយ បានពូត្រឡប់មក?

ខាៈ ហ្នឹងហើយ ប៉ុនតែគេអត់មាននៅនេះទេ វៀតណាមមិនដឹងនៅឯណាទេ ។

ជាតិៈ ពូ ចុះមក មានជួប វៀតណាមតាមផ្លូវទេ?

ខាៈ ប៉ុនតែបានយាយខ្ញុំ គាត់ចេះ ។

ជាតិៈ ចេះវៀតណាមអេ?

ខ: ហ្នឹងហើយប៉ុនតែជួប ជួបផ្លូវ រត់មកវិញដដែល រត់ទៅក៏ផ្លូវហ្នឹង មកវិញក៏ផ្លូវហ្នឹង ជិតមកដល់ផ្ទះបានជួបគ្នា ជួបគ្នា បានខ្ញុំត្រឡប់ ដល់ឆ្នាំ៨០ ខ្ញុំទៅធ្វើទាហានរហូតទៅ ។

ជាតិ: អញ្ចឹង ពូធ្វើទាហានហ្នឹង គេចាប់ ឬមួយក៏បង្ខំចិត្តឬមួយក៏ស្ម័គ្រចិត្ត?

ខ: អត់ចាប់ខ្ញុំទេ ។

ជាតិ: ហេតុអីចង់សងសឹក?

ខ: គំនិតមុនដំបូង ថាចង់សងសឹកដែរ ប៉ុន្តែដេកគិតយូរៗទៅ ហើយខ្ជិលសងធ្វើអី គិតទៅផ្លូវធម៌ ផ្លូវលោកសិនទៅ

ជាតិ: បាទ ។

ខ: យើងធ្វើអី កម្មពៀរគេទៅទៀត ក៏មិនកើតដែរ ខុះអី អ្នកខ្ញុំត្រូវសងសឹកហ្នឹង នៅក្នុងស្រុកនៅក្នុងភូមិ ឥលូវ វាស្លាប់ឯងហើយ ។

<u>Cassette II</u>
<u>Side A</u>

ខ: ហ្នឹងដល់តែពេលដេកគិតឃើញ អញឈាមសង បំណុលឈាមវិញ ដូចមិន កើតសោះ អញ្ចឹង កុំអីទុកអើយ រុកតាមកំលាំងជីវោ របស់គាត់ទៅ ។

ជាតិ: បាទ ។

ខ: បើគាត់ស្លាប់ដោយសារ គេសម្លាប់គាត់ វិញ ក៏ស្លាប់ទៅ កុំអោយ យើងយក កំហឹងទល់ កំហល់ ទៅសម្លាប់គាត់ ខ្ជិល ។

ជាតិ: និយាយពី ខែ៨ ពូ មកវិញហ្នឹងអា៎ ដូចថាបានជួបបងប្អូនអី ទាំងអស់គ្នាទេ?

ខ: ជួបទាំងអស់ បងប្អូនខ្ញុំ ។

ជាតិ: ជួបទាំងអស់ណោះ ។

ខ: បាទ ។

ជាតិ: ឥលូវ បើសម្លាប់ទៅ ស្លាប់ប៉ុន្មាននាក់ គ្រួសារពូ?

ខ: បងប្អូនខ្ញុំស្លាប់ មើល ឪពុកហើយនិងបងថ្លៃ ហើយ ប្អូនៗ បីនាក់ ៥នាក់ ។

ជាតិ: ប្អូនបីនាក់?

ខ: ហ្នឹង ។

ជាតិៈ ប្អូនបីនាក់ហ្នឹង ។

ខាៈ ប្អូនពីរ ក្មួយមួយ ។

គៀនៈ តាមពិត តែពីរទេ ឪពុកបី ពីរទៀត សាច់ថ្លៃ ។

ជាតិៈ ហ្នឹងហើយ ។

ខាៈ ហើយអាប្អូនប្រុសខ្ញុំ ហ្នឹង វាសម្លាប់ ខ្លួនវានៅភ្នំពេញនេះ ។

ជាតិៈ សម្លាប់ខ្លួនក្រោយ ។

ខាៈ វាដូរចត់ដែរហ្នឹង បងប្អូនខ្ញុំ វាលំបាក វេទនា ។

ជាតិៈ អឺ ច្បាស់ថា យកទៅសម្លាប់ប៉ុន្មាននាក់ដែរអ្នកដែលស្លាប់ហ្នឹង?

ខាៈ យកទៅសម្លាប់ផ្ទាល់ នៅក្នុងហ្នឹង បងខ្ញុំ ហើយនិងឪពុកខ្ញុំ ត្រូវគេសម្លាប់ផ្ទាល់ ហើយ អាតូចៗអាហ្នឹង វាអត់ទឹកដោះ វាអត់បាយ ។

ជាតិៈ អូ! អញ្ចឹងទេអេ សម្លាប់ផ្ទាល់ តែពីរនាក់ទេ ។

ខាៈ ហ្នឹងហើយ ។

ជាតិៈ បងថ្លៃហើយ និងឪពុកបង្កើត ។

ខាៈ ហ្នឹងហើយ ម្ដាយធំ មួយគ្រួសារអាហ្នឹងគេសម្លាប់ផ្ទាល់ហើយ ហ្នឹងគ្រួសារកូនគាត់ប៉ុន្មាន នាក់ ខ្ញុំអត់ចាំទេ ដឹងតែមួយគ្រួសារហ្នឹងតែម្ដង អស់រលីងមួយពូជ ។

ជាតិៈ នឹកដល់សម័យខ្មែរក្រហម ពូឈឺចាប់អីជាងគេ? នឹកដល់សម័យនៅក្នុងគុកហ្នឹង?

ខាៈ នឹកឃើញអារឿងគេអត់អោយបាយស៊ីហ្នឹងតែម្ដង ។

គៀនៈ ឈឺចាប់ គេអត់អោយបាយស៊ី?

ខាៈ បាទ ។

គៀនៈ ហើយចុះអារឿងគេយកពុកពូអី?

ខាៈ អេ! នឹកឃើញដែរ ហ្នឹងនឹកឃើញ ឈឺចាប់ដែរ ប៉ុន្តែវាធ្វើម៉េច ការកន្លងហួសហើយ កម្មពៀរបស់គាត់ ខ្ញុំនិយាយតែប៉ុណ្ណឹង ។

ជាតិៈ ហ្នឹងហើយ គិតរឿងកម្មពៀរ មកវិញ?

ខាៈ ហ្នឹងហើយ ។

ជាតិៈ ប៉ុន្តែពេលត្រឡប់មកវិញ ចង់សងសឹកដែរ?

ខា៖ ចង់ដែរ ប៉ុនតែណាមួយ រាជរដ្ឋាភិបាល គេស្រែកផង ឈាម កំដឈាមបន្តិចទៅ ។

ជាតិ៖ ពី ៧៩ ហ្នឹងមក?

ខា៖ ណាមួយយើងចិត្តអត់ដាច់ ទៀតហើយ ស្តាយអត់កើត ។

ជាតិ៖ ហើយចុះពេលចេញពីគុកមកស៊ី សាំន់ សាំង អីនៅស្រុកកំណើតហ្នឹង ឬក៏រត់ទៅណាទៅ?

ខា៖ គេគេចដែរហ្នឹង ។

ជាតិ៖ គេចរយៈពេលយូរអេ ឆាប់ដែរ?

ខា៖ រយៈពេលយូរ រយៈវែង ខ្ញុំអត់ដឹងទេ រយៈយូរ រយៈវែង ខ្ញុំអត់ដឹងទេ ព្រោះសម័យ គេសុខស្រួលដែរហើយទេ ។

ជាតិ៖ ជួបគ្នាហ្នឹង សុខស្រួលដែរហើយអេ?

ខា៖ ហ្នឹងហើយ សម័យខ្ញុំធ្វើការដែរហើយ ស្រករខ្ញុំដើររកគេ និយាយរួម ខ្ញុំដើររកតែម្តង ។

គឿន៖ ហើយចុះពូ ខ្ញុំចង់សួរពូបន្តទៀត ទាក់ទងនឹងទស្សនៈរបស់ពូផ្ទាល់ តាំងពីមុនរហូតមកដល់ ឥលូវហ្នឹង ពូមានដែលធ្លាប់លឺ ពីខាងរាជរដ្ឋាភិបាលហើយអង្គការសហប្រជាជាតិ គេមាន គំរោងចង់បង្កើតតុលាការកាត់ទោស មេដឹកនាំខ្មែរក្រហម ពូមានដែលធ្លាប់លឺទេ?

ខា៖ ខ្ញុំធ្លាប់លឺដែរ ។

គឿន៖ លឺតាំងពីពេលណាមកពូ?

ខា៖ តាំងពីសម័យខ្មែរក្រហមចូលស្រុក ។

គឿន៖ ឆ្នាំណា?

ខា៖ ឆ្នាំ៩៣ អេ ៩៤ទេ ខ្មែរក្រហម ចូលស្រុកផង ។

គឿន៖ គេប្រុងកាត់ទោស តាំងពីពេលហ្នឹង?

ខា៖ ហ្នឹងហើយ ។

គឿន៖ ពូលឺ លឺតាមគេនិយាយតៗគ្នា ឬក៏តាមវិទ្យុ?

ខា៖ តាមវិទ្យុទូរទស្សន៍ គ្រប់មជ្ឈដ្ឋាន ទាំងអស់ ទាំងអី ទាំងអស់ហ្នឹង ។

គឿន៖ អូ ។

ខា៖ អត់មាន តាមមាត់ចាប មាត់ព្រាបគេទេ ឃើញទាំងទូរទស្សន៍ ទាំងកាសែតអន្តរជាតិក៏ ស្អីទាំងអស់គ្នា ទាំងអស់ហ្នឹង

គឿនៈ ហើយចុះពូមានដែលធ្លាប់លឺឈ្មោះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទេ អ្នកធំៗ ពូមានដែលលឺទេ?

ខាៈ គ្រាន់តែលឺ ប៉ុនយើងម៉េចឃើញមុខគេ ទោះអូនឯងក៏មិនដែលស្គាល់ដែរ អូនឯងដើរធ្វើការហ្នឹង ក៏មិនស្គាល់ដែរ លឺពីជាន់មុន ដឹងតែ ហ៊ូ យ៉ុន, ហ៊ូ នឹម, ខៀវ សំផន ទេ នួន ជា, នួន ប៉ែត អីឯណា ខ្ញុំអត់ដែលដឹងទេ ខ្ញុំដឹងតែ ហ៊ូ យ៉ុន, ហ៊ូ នឹម លាក់ខ្លួន នៅក្នុងស្រុកខ្ញុំទេ ដ្កាអូ ។

គឿនៈ ហើយលឺពីណាទៀត?

ខាៈ ក្រោយមក ខ្ញុំអត់ដែលដឹង ក្រោយពី៧៦, ៧៩នេះ មានលឺសូរ ឈ្មោះ ប៉ុល ពត, អៀង សារីនេះ តែម្តង ។

គឿនៈ ហើយចុះហ៊ូ យុន, ហ៊ូ នឹមហ្នឹង ដឹងតាំងពីពេលណា?

ខាៈ ដឹង តាំងពីឆ្នាំ ៧០ ។

គឿនៈ តាំងពី៧០ ។

ខាៈ ហ្នឹងហើយ ។

គឿនៈ ហើយចុះពូមានដឹង ថា ប៉ុល ពត, អៀង សារី, ខៀវ សំផន ហ្នឹង គាត់មានតួនាទី អីខ្លះ ហើយ ហ៊ូ យ៉ុន, ហ៊ូ នឹម ហ្នឹង គាត់ធ្វើអីខ្លះ កាលពីមុនមក?

ខាៈ ពីមុន ខ្ញុំដឹងដែរ ។

គឿនៈ ពេលពូដឹងហ្នឹង គាត់កំពុងតែធ្វើអី ពេលហ្នឹង?

ខាៈ ហ៊ូ យ៉ុន, ហ៊ូ នឹម គាត់ខាងអី ខ្ញុំអត់សូវដឹងទេ ប៉ុនតែដឹងថាគេតស៊ូហើយ ពីរនាក់ហ្នឹង បីនាក់ហ្នឹង,

គឿនៈ ហើយចុះប៉ុល ពត?

ខាៈ ប៉ុល ពត ខ្ញុំអត់ដឹងទេ ខ្ញុំអត់ដឹងតែម្តង ។

គឿនៈ ហើយអៀង សារី ធ្វើអី?

ខាៈ អៀង សារី យើងដឹងសម័យគេហ្នឹង ខាងឧបនាយករដ្ឋមន្ត្រី ។

គឿនៈ ឧបនាយករដ្ឋមន្ត្រី ។

ខាៈ ហ្នឹងហើយ ។

គឿនៈ ហើយចុះខៀវ សំផន?

ខាៈ ខៀវ សំផន ខ្ញុំអត់ដឹង ស្រាប់តែបាត់ឈ្មោះ ពីសម័យកាលប៉ុល ពត ចូលបាត់ឈ្មោះតែម្តង ។

គឿនៈ ហើយចុះតាម៉ុក អី មានដឹងទេ?

ខាៈ តាម៉ុក គ្រាន់តែដឹង ។

គឿនៈ ដឹងកាន់ខាងអី?

ខាៈ កាលហ្នឹងដឹង ដឹងកាន់ខាងទ័ព ។

គឿនៈ តាម៉ុក ខាងទ័ព ។

ខាៈ ហ្នឹងហើយ ។

គឿនៈ ខាងតំបន់ណា?

ខាៈ តំបន់ភូមិភាគនិរតី ។

គឿនៈ គេហៅតំបន់លេខប៉ុន្មាន?

ខាៈ ភូមិភាគនិរតី មិនដឹងជាតំបន់លេខប៉ុន្មានទេ ខ្ញុំអត់ដឹងដែរកាលហ្នឹង និយាយរួមគាត់ក្តាប់ទាំងទ័ព ទាំងប្រជាជន តាម៉ុក ភូមិភាគនិរតីហ្នឹង ។

គឿនៈ ហើយចុះពូ រហូតមកដល់ឥលូវហ្នឹង ពូមានបានដឹងថា ឈ្មោះអ្នកមេដឹកនាំជាន់ខ្ពស់ហ្នឹងអ្នកណាខ្លះ នៅរស់ អ្នកណាខ្លះស្លាប់ ហើយអ្នកណាខ្លះ គេចាប់ដាក់គុក ពូមានដឹងទេ?

ខាៈ ចាប់ដាក់គុក ដឹងតែតាម៉ុក ហើយអីគេ ។

គឿនៈ ឌុច?

ខាៈ ឌុច ខ្ញុំអត់ដែលដឹងដែរទេ ខ្ញុំដឹងតែនួន ប៉ែត ហើយមេដឹកនាំ ទើបតែសារក្រោយនេះទេ ។

គឿនៈ ហើយចុះអ្នកណាខ្លះដែលស្លាប់ហើយអ្នកណាខ្លះដែលនៅរស់?

ខាៈ ស្លាប់ដឹងអី សុន សេន ហើយ ។

គឿនៈ សុន សេន ស្លាប់?

ខាៈ ស្លាប់ហើយ ។

គឿនៈ ហើយចុះប៉ុល ពត?

ខា: ប៉ុល ពត ហ្នឹង ខ្ញុំមិនដឹងស្លាប់ ឬក៏រស់ទេ ខ្ញុំអត់ដឹងទេរឿងហ្នឹង ព្រោះខ្ញុំឃើញនៅក្នុងកាសែត ឃើញមួយដង ស្លាប់ សក់ស ម្តងសក់ខ្មៅអញ្ចឹង ខ្ញុំឆ្ងល់ដែរ ខ្ញុំឆ្ងល់ថាមួយដង សក់ស មួយដងសក់ខ្មៅ ខ្ញុំឆ្ងល់ត្រង់ហ្នឹង នៅក្នុងកាសែត ក្នុងកាសែត ខ្ញុំឆ្ងល់ត្រង់ហ្នឹង ខ្ញុំមើលនៅក្នុងកាសែត ។

គឿនៈ ប៉ុល ពតស្លាប់បាត់ហើយពូ ។

ខា: ហ្នឹងហើយ ខ្ញុំដឹងថាគេស្លាប់ដែរ ប៉ុន្តែ មួយដងសក់ស មួយដងសក់ខ្មៅអញ្ចឹង ។

គឿនៈ ហើយចុះពូដូចពូលឺតាំងពី៩០ជាង ថាគេបំរុងមានតុលាការបង្កើតដើម្បីកាត់ទោសមេដឹកនាំ ខ្មែរក្រហមអញ្ចឹង ហើយរហូតមកដល់ពេលហ្នឹង អត់ទាន់មានដំណើរការហ្នឹងអញ្ចឹង ពូគិតថាយ៉ាងម៉េចបានជាវាអត់កើតនៅក្នុងគំនិតរបស់ពូ?

ខា: គំនិតរបស់ខ្ញុំ អានេះរឿងគេ នយោបាយរបស់គេ អាហ្នឹងត្រូវឬអត់ ។

គឿនៈ គេចង់អោយកើតដែរឬអត់?

ខា: គេចង់អោយកើតដែរ ប៉ុន្តែគេរកគន្លិះអោយយូរ អោយចំណេញនៅក្នុងស្រុកខ្មែរផង ។

ជាតិ: អោយូរចំណេញស្រុកខ្មែរ?

ខា: ទុកយូរវាចំណេញខ្លះដែរ ។

ជាតិ: ចំណេញអី?

ខា: សេដ្ឋកិច្ច នាំចូលមកខ្លះ អីខ្លះ ថវិការខ្លះមក ។

គឿនៈ ហ្នឹងជាគំនិតរបស់ពូអី?

ខា: ហ្នឹងហើយ ។

គឿនៈ ហើយចុះបើសិនជាតុលាការហ្នឹងកើតមាន គំនិតរបស់ពូ ចង់អោយពេលកាត់ទោសហ្នឹង ពូចង់ដឹងចង់លឺដែររឺអត់?

ខា: ចង់ដឹងដែរហ្នឹង ។

គឿនៈ ចង់ដឹង ចង់លឺ ចង់ឃើញគេកាត់ទោសហ្នឹង?

ខា: ហ្នឹងហើយ ។

គឿនៈ ហើយចុះពូដូចថាពូចង់អោយគេផ្សព្វផ្សាយតាមណា ដូចថា តាមវិទ្យុ ឬក៏តាមទូរទស្សន៍?

ខា: តាមទូរទស្សន៍ទៅ មានអី ឥលូវមានតែទូរទស្សន៍ទេ ។

គឿនៈ ហើយចុះហេតុអីបានជាពូចង់ដឹងចង់លឺអញ្ចឹង?

ខាៈ ចង់មើលទៅ ដឹងថា តើគេកាត់ហ្នឹង វាយុត្តិធម៌ដែរឬអត់ កាត់អន្តរជាតិ ឬកាត់មួយយ៉ាងណាវិញ

គឿនៈ ហើយចុះពូយល់ថាការដែលនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោសហ្នឹង ពូយល់ថាវាជាការចាំបាច់សំរាប់ពូទេ?

ខាៈ ចាំបាច់ដែរ ។

គឿនៈ ចាំបាច់យ៉ាងម៉េចទៅពូ?

ខាៈ ដោយជន៣លាននាក់ដែលស្លាប់រង្គាលអត់ដោយទោសពៃរ៍អី ។

គឿនៈ ចង់អោយគេរកយុត្តិធម៌អោយអ្នកបីលានហ្នឹងអេ?

ខាៈ ហ្នឹងហើយ ។

គឿនៈ ហើយចុះពូ យល់ថា តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមហ្នឹងអាចកើតមានទេ?

ខាៈ អាចកើត ប៉ុនថ្ងៃណា ។

គឿនៈ ហើយចុះពូថា អាចកើត?

ខាៈ អាចកើតបាន ព្រោះមានអង្គការសហប្រជាជាតិ ។

គឿនៈ នៅក្នុងហ្នឹងដែរ?

ខាៈ ហ្នឹងហើយ បើមិនមានអត់កើតទេ ។

គឿនៈ ពូអញ្ចេះ តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលគេបំរុងនឹងបង្កើតឡើងហ្នឹង គេចង់តែកាត់ទោស មេដឹកនាំខ្មែរក្រហមកំពូលៗទេណា តើបើតាមគំនិតពូចង់អោយគេកាត់ទោសអ្នកដែលតូចៗដែលយកឪពុកពូទៅ កាត់ទោសអ្នកហ្នឹងដែរ ឬអត់?

ខាៈ ចង់ដែរ ។

គឿនៈ ចង់ដែរ ។

ខាៈ បាទ ។

គឿនៈ ហេតុអីពូ?

ខ: ព្រោះរឿងថ្នាក់លើ គេនិយាយប្រវែងតែមួយចន្លោមទេ ដល់តែថ្នាក់ក្រោមនិយាយមួយហាត់ ។

គឿន: ហើយចុះបើសិនជាតុលាការហ្នឹងកើតឡើងមែនពូជឿថាតុលាការហ្នឹង អាចរកយុត្តិធម៌ ជូនពូ ឬក៏ដូចជាប្រជាជន ឬជនរងគ្រោះទាំងឡាយបានដែរឬអត់?

ខ: រកឃើញ ។

គឿន: ហេតុអីបានជាពូយល់ថា អាចរកយុត្តិធម៌ជូនបាន?

ខ: អង្គការសហប្រជាជាតិ ហើយនិងរដ្ឋាភិបាលយើងថ្មី ។

គឿន: ហើយចុះដែលធ្លាប់លឺពាក្យយុត្តិធម៌ទេ ពូដែលឈឺឈ្មោះហ្នឹងទេ?

ខ: ពាក្យយុត្តិធម៌ពាក្យមិនត្រឹមត្រូវ ។

គឿន: យុត្តិធម៌?

ខ: អយុត្តិធម៌ ។

គឿន: យុត្តិធម៌ ។

ខ: យុត្តិធម៌ពាក្យត្រឹមត្រូវ ។

គឿន: ហើយចុះពូ ដែលធ្លាប់លឺពាក្យថា ផ្សះផ្សារបង្រួបបង្រួមជាតិអាំពូ?

ខ: លឺ ។

គឿន: ពាក្យហ្នឹងបានន័យថាម៉េច ពាក្យផ្សះផ្សារបង្រួបបង្រួមជាតិ?

ខ: បង្រួបបង្រួមជាតិ គឺដើម្បីចាប់ដៃគ្នា កសាងប្រទេស ។

គឿន: ចាប់ដៃគ្នាកសាងប្រទេស ។

ខ: បាទ ។

គឿន: ហើយចុះពូ នៅក្នុងភូមិ ឃុំ ពូដែលរស់នៅហ្នឹង មានការផ្សះផ្សារគ្នាហើយឬនៅ?

ខ: មានហើយ ។

គឿន: មានហើយ?

ខ: បាទ ។

គឿន: ត្រង់ចំនុចណាខ្លះដែលពូយល់ថា ជាការផ្សះផ្សារបង្រួបបង្រួមជាតិ?

ខ: ផ្សះផ្សារជាតិ ត្រង់ថា មិនសងឈាមគ្នា មិនសងសឹក គឺមិនគុំគួនគ្នាទេ ។

គឿនៈ អញ្ចឹងបានន័យថា នៅក្នុងភូមិដែលពូរស់នៅហ្នឹង ទាំងឃាតករ ទាំងជនរងគ្រោះនៅជាមួយគ្នា?

ខាៈ ហ្នឹងហើយ ចាប់ដៃគ្នា កសាងមាតុភូមិយើងឡើងវិញទៅ ។

គឿនៈ បាទ ។

ខាៈ មិនអោយអ្នកសងសឹក មិនអោយអ្នកណាគុំគួន ដាក់អ្នកណាមួយ ។

គឿនៈ ហើយចុះពូយល់យ៉ាងម៉េចដែរចំពោះយើង រាជរដ្ឋាភិបាលយើងសព្វថ្ងៃហ្នឹង គេធ្វើការផ្សះផ្សារបង្រួបបង្រួមជាតិជាមួយ នឹងខ្មែរក្រហមដែលធ្លាប់តែធ្វើទុក្ខបុកម្នេញ កាប់សម្លាប់ប្រជារាស្ត្រអញ្ចឹង ពូយល់យ៉ាងម៉េចដែរចំពោះរាជរដ្ឋាភិបាលយើងឥលូវដែលធ្វើការផ្សះផ្សារបង្រួបបង្រួមជាតិ?

ខាៈ ខ្ញុំយល់ឃើញ បង្រួបបង្រួមជាតិ តែមេដឹកនាំខ្មែរក្រហមយើងសព្វថ្ងៃហ្នឹង ដើម្បីទឹកដីខ្មែរយើង ។

គឿនៈ ហើយចុះពូយល់ថា មេដឹកនាំជាន់ខ្ពស់ធំៗហ្នឹង គួរអត់អោនទោសអោយបានដែរឬអត់?

ខាៈ ស្រាច់តែ ។

គឿនៈ តែចង់ដឹងពីគំនិតរបស់ពូ?

ខាៈ គំនិតខ្ញុំ ។

គឿនៈ បាទ ។

ខាៈ ខ្ញុំគិតអត់ចេញទេហ្នឹង ។

គឿនៈ ពូ ចង់ ចិត្តពូអ៉ា ចង់អោយគេរួចទោស ឬក៏ចង់អោយគេដាក់ទោស?

ខាៈ តែមានទោស ត្រូវតែទទួលទោសខ្លះ ។

គឿនៈ ហើយចុះបើសិនជាកាត់ទោសហ្នឹង វាធ្វើអោយមានការប៉ះពាល់ដល់ការផ្សះផ្សារបង្រួបបង្រួមជាតិ?

ខាៈ ប៉ះ ។

គឿនៈ ពូជឿថាប៉ះអញ្ចឹងតែម្តង?

ខាៈ ហ្នឹងហើយ ។

ជាតិៈ ប៉ុន្តែដោយសារមានទោសត្រូវតែកាត់ ។

ខ: ហ្នឹងហើយ ។

គឿន: ហើយចុះពូយល់ថាសាសនាអាចតួនាទីនៅក្នុងការផ្សះផ្សារបង្រួបបង្រួមជាតិនៅក្នុងប្រទេសយើងដែររឺអត់?

ខ: សាសនា ។

គឿន: សាសនា ទៅវត្តទៅអី សាសនាព្រះពុទ្ធយើងហ្នឹង ។

ខ: មាន ។

គឿន: មានត្រង់ណាពូ?

ខ: មានផ្លូវធម៌ ផ្លូវព្រះពុទ្ធហ្នឹង ។

គឿន: ចំនុចត្រង់ណាពូអាចលើកបានទេថា ចំនុចហ្នឹងអាចធ្វើអោយជនរងគ្រោះ ជនដៃដល់ អាចរស់នៅជាមួយគ្នាបានសុខបាន ពូយល់ថាចំនុចត្រង់ណាដែលសាសនាព្រះពុទ្ធយើងលើកមក?

ខ: នៅជឿនៅក្នុងព្រះពុទ្ធសាសនា នៅក្នុងផ្លូវធម៌ ផ្លូវលោក ។

គឿន: បាទ ផ្លូវធម៌ គេថាយ៉ាងម៉េច អោយយើងនៅដោយស្ងប់ចិត្តបាន?

ខ: អោយរំងាប់ដោយពៀរ ចងពៀរហ្នឹង ។

គឿន: ពៀរ ចងពៀរ ។

ខ: បាទ ។

គឿន: ហើយចុះពៀររំងាប់ដោយការមិនចងពៀរហ្នឹងបានន័យថាម៉េចពូ?

ខ: មិនគុំគួនគ្នា កុំសម្លាប់គ្នាទៅវិញទៅមក ។

គឿន: បាទ ចំនុចត្រង់ហ្នឹងហើយ ដែលអាចទាញអោយយើងនៅជាមួយគ្នាបានសុខ អត់អោនទោសអោយគ្នា បានផ្សះផ្សារគ្នាបាន?

ខ: ហ្នឹងហើយ ។

គឿន: ហើយចុះពូយល់ថា បើសិនជា យកមេដឹកនាំជាន់ខ្ពស់មកកាត់ទោសហ្នឹង វាជាការសងសឹកដែររឺអត់?

ខ: ការសងសឹកដែរ ។

គឿន: ការសងសឹកដែរ?

ខា: បាទ ។

គឿន: ហេតុអីបានជាពូយល់ថាជាការសងសឹក?

ខា: ហើយចុះកាលហ្នឹង គ្នាខុសហើយ យើងយកកំហុសគ្នាមកទៀត យើងមិនអនុគ្រោះគ្នាវិញ ។

គឿន: មកដល់សព្វថ្ងៃហ្នឹងពូ បើសិនជាពូបានដឹង បានលឺបានស្គាល់អ្នកដែលសម្លាប់ឪពុក ពូដោយផ្ទាល់ដៃ ហើយគាត់នៅរស់ ពូចង់សងសឹកគាត់វិញដែរឬអត់?

ខា: ដល់ឥលូវ ខ្ញុំគ្រាន់តែ រឿងឃើញផ្ទាល់ក៏ខ្ញុំថា អ្នកនៅសម្លាប់ផ្ទាល់តែម្តង ខ្ញុំអត់សងសឹកទេ ព្រោះនេះប្រៀបធៀបដូចជា យើងដឹកគោ អោយចាម ។

គឿន: ដឹកគោអោយចាម ។

ខា: ចាមកាប់គោ យើងអ្នកទិញទៅអោយ ។

ជាតិ: អញ្ចឹងយើងអត់មានខុសទេ ។

ខា: យើងអត់ខុសទេ ។

ជាតិ: ចាមអ្នកកាប់គោ ហើយគាត់គ្រាន់តែអ្នកកាប់គោអោយចាមទេ ។

ខា: ហ្នឹងហើយ ដូចចោរលួចអញ្ចឹង លួចយកអោយចាម ។

ជាតិ: តែចោរអត់ខុសទេ?

ខា: អ្នកកាប់មានខុសអីវា ។

គឿន: ហើយអញ្ចឹងពូអត់ចង់សងសឹកអ្នកដែលសម្លាប់ឪពុកពូទេ?

ខា: ខ្ញុំ អត់សងទេ គេវា ។

គឿន: តាមបញ្ជារគេ ។

ខា: តាមបញ្ជារគេដែរ ។

គឿន: តែពេលបែកភ្នាម ម៉េចបានពូប្រាប់ខ្ញុំតាំងពីដើមមក ថាពូចង់តាមរកមុខអ្នកហ្នឹង?

ខា: ខ្ញុំរកមុខហ្នឹង ដូចរកមុខអរគុណគេទេអាហ្នឹង ។

ខា: ព្រោះ អ្នកហ្នឹងក៏អោយខ្ញុំរស់ដែរ អ្នកបុគ្គលិកហ្នឹង ។

គឿន: រកមុខអរគុណមិនមែនរកមុខនេះទេ ចូលធ្វើទាហាន ដើម្បីរកមុខអរគុណគេទេ?

ខា: ធ្វើទាហានខ្ញុំសងសឹកដោយសារ ពួកអាតាមនៅតាមមូលដ្ឋាននេះ ។

គឿនៈ សងសឹកអ្នកនៅមូលដ្ឋានហ្នឹងវិញ ។

ខាៈ ហ្នឹងហើយ ព្រោះអ្នកឯងបញ្ជូនខ្ញុំអោយទៅហ្នឹង ។

គឿនៈ ពូអំបាញ់មិញថា អ្នកតូចតាចអត់ចង់ទេ ចង់រកអាអ្នកធំៗវិញ?

ខាៈ អ្នកធំថ្នាក់លើ ខ្ញុំមិននិយាយទេ ទៅនិយាយអី សំខាន់បំផុត តូចតាចនៅនេះហ្នឹង ។

ជាតិៈ រម៉េករម៉ក?

ខាៈ រម៉េករម៉កនេះ វាខូចមាត់ វៀចមាត់ ក្រាញនេះ មាត់វែង មាត់ខ្លី ។

គឿនៈ ហើយចុះពូមានដែលទៅចូលរួមទិវាចងកំហឹង ២០ ឧសភាហ្នឹង ពូមានដែលទៅចូលរួមនឹងគេទេ?

ខាៈ ដែល ។

គឿនៈ ចូលរៀងរាល់ឆ្នាំតែម្ដងអេពូ?

ខាៈ ឆ្នាំណា ខ្ញុំត្រូវទៅ ទៅ ឆ្នាំណាខ្ញុំ អត់បានទៅ អត់បានដែរហ្នឹង ។

គឿនៈ ហើយចុះពូ ចង់អោយទិវាហ្នឹង មានតទៅទៀត ឬក៏ចង់បញ្ឈប់អាទិវាចងកំហឹងហ្នឹង?

ខាៈ ចង់អោយមានតទៅទៀត ។

គឿនៈ ហេតុអីបានជាពូចង់អោយមានទិវាហ្នឹងតទៅមុខទៀត?

ខាៈ អោយក្មេងជាន់ក្រោយវាដឹង ។

គឿនៈ ដឹង ។

ខាៈ កុំអោយវាកើតឡើងតទៅវិញ ។

គឿនៈ ហើយចុះពូយល់ថា ចំពោះប្រទេសខ្មែរយើងសព្វថ្ងៃនេះ គួរតែធ្វើយ៉ាងម៉េចទៅដើម្បីកុំអោយខ្មែរ ខ្មែរ ហ្នឹង វាលែង កាប់ សម្លាប់គ្នាទៅវិញទៅមក?

ខាៈ អោយផ្សះផ្សារគ្នា ។

គឿនៈ បាទ! អោយផ្សះផ្សារគ្នា តាមរបៀបវិធីសាស្រ្តយ៉ាងម៉េចទៅ?

ខាៈ រឿងហ្នឹង ខ្ញុំអត់ និយាយបានចេះ ។

គឿនៈ និយាយតាមគំនិតពូ សម័យបំផុត ពូថាធ្វើម៉េច កុំអោយសងសឹកគ្នា?

ខាៈ ខ្ញុំដោះស្រាយអត់ចេញទេ ។

គឿនៈ ហើយចុះពូ ពូយល់យ៉ាងម៉េចដែរ ពូនៅសុខៗខ្ញុំមកសួរនាំ ពីការឈឺចាប់លំបាក វេទនា កាលពី សម័យខ្មែរក្រហមមក ពូមានអារម្មណ៍យ៉ាងម៉េចដែរ?

ខាៈ យល់ថា ខាងរដ្ឋាភិបាល ក្រៅរដ្ឋាភិបាល គេចង់រកការពិត ពួកសម្លាប់ប្រជារាស្ត្រខ្មែរ បីលាន ។

គឿនៈ ហើយចុះពូយល់យ៉ាងម៉េចដែរ?

ខាៈ យល់ថាគេចង់គាស់រំលើងអោយក្មេង ជំនាន់ក្រោយវាដឹងលឺដង កុំអោយវាបាត់ សម័យ អាពតក្មេង សម្លាប់ក្មេង ។

គឿនៈ ហើយចុះពូ អារឿងឈឺចាប់ អារឿងលំបាកវេទនា នៅក្នុងសម័យប៉ុល ពត មានដែល ចេះតែ រំខាន ដល់អារម្មណ៍ពូ ធ្វើការសព្វថ្ងៃទេ?

ខាៈ រំខានដែរ ។

គឿនៈ រំខានរបៀបម៉េចទៅពូ?

ខាៈ ពេលណាយើងនឹកឃើញឪពុកយើងស្លាប់បាត់ទៅ យើងនឹកឃើញថាអីបើឪអញនៅ ទៅ សប្បាយនឹងគេ បើអញអត់ឪពុកអញហ្នឹង ឃើញគេអញ្ចឹងទៅ ឃើញគេធ្វើការ រកស៊ីបាន ទៅ យើងទាល់តែយើងអត់ទៅវិញ បើឪពុកយើងនៅ យើងសប្បាយហើយ យើង ត្រូវរកបានទៀត គាត់ជួយដឹកនាំរកស៊ីហ្នឹង ។

គឿនៈ យូរៗ នឹកឃើញអញ្ចឹង ពិបាកចិត្តមួយដង មួយដង ដែរ?

ខាៈ ឃើញ បុណ្យទានគេអីអញ្ចឹងទៅ ហើយពេលគេរៀបការឃើញបងប្អូនកូនក្មួយការអញ្ចឹង ទៅឃើញជីដូន ជីតាមា កុងអញ្ចឹង ឃើញឪយើងជួបជុំគ្នា ខ្ញុំអារម្មណ៍ នឹកឃើញថា ។

គឿនៈ កុកកួលនៅក្នុងដែរ?

ខាៈ ហ្នឹងហើយ ។

គឿនៈ ហើយចុះពេលដែលពូ លំបាកចិត្ត គឺងទ្រូងអីអញ្ចឹង ពូមានវិធីសាស្ត្រយ៉ាងម៉េចដែរ ដើម្បីអោយវាបានធូរទៅវិញ ពូធ្វើយ៉ាងម៉េចទៅរៀងរាល់ពេលដែលពូពិបាកចិត្តអញ្ចឹង?

ខាៈ នៅអោយស្ងៀមទៅ ។

គឿនៈ នៅអោយស្ងៀម ។

ខាៈ បាទ ។

គឿនៈ ហើយចុះមានវិធីអីទៀតទេ?

ខាៈ ខ្ញុំ អត់មានវិធីអីទេ ខ្ញុំដេកអោយស្ងៀមតែម្តង ។

គឿនៈ តែពិបាកនៅអោយស្ងៀមវាធូរទៅខ្លួនឯងតែម្តង ។

ខាៈ ដើរទៅនេះ ទៅនោះ ។

គឿនៈ អូ ដើរទៅនេះ ទៅនោះវាអាចធូរ ។

ខាៈ ហ្នឹងហើយ ។

គឿនៈ ហើយចុះពូពេលដែលពិបាកចិត្ត ពូមានដែលទៅៗ ជួបគ្រូពេទ្យខាងផ្នែកផ្លូវចិត្តហ្នឹងនិយាយអី?

ខាៈ អត់ដែលទេ ។

គឿនៈ អត់ដែល ធ្លាប់តែនិយាយជាមួយស្រុក ភូមិ អញ្ចឹង?

ខាៈ ហ្នឹងហើយ ។

គឿនៈ និយាយទៅបានធូរទេ?

ខាៈ ធូរអញ្ចឹងដែរ ។

គឿនៈ អូ ហើយចុះពូយល់ថាសាសនាព្រះពុទ្ធអាចជួយពេលពូលំបាកចិត្តអញ្ចឹងបានទេ ដូចជាទៅវត្តទៅអី អាចជួយបានទេ?

ខាៈ ជួយបាន សូត្រធម៌ ទៅរៀនដោះស្រាយ ដោយពៀរ រំងាប់ដោយការមិនចងពៀរហ្នឹងកម្មរបស់គាត់ទេ ។

គឿនៈ អូ ពូនឹកឃើញ អញ្ចឹងទៅ ធ្វើអោយពូធូ?

ខាៈ ហ្នឹងហើយ ។

គឿនៈ ហើយចុះពូពាក្យថាការពិតបានន័យថាម៉េចពូ?

ខាៈ ការពិត ខ្ញុំ បកស្រាយអត់ចេញទេអាហ្នឹង ។

គឿនៈ ចង់និយាយចង់ដឹងថាការពិត ពាក្យថាពិត បានន័យថាម៉េចពាក្យហ្នឹង?

ខាៈ ពិតគឺមែន ។

ជាតិៈ ដោះស្រាយអត់ចេញទេអាហ្នឹង ។

ខាៈ ការពិតហើយ ។

ជាតិៈ មិនចាំបាច់ដោះស្រាយអីទេ ។

ខាៈ វាមិនធ្លាប់រៀន ។

គឿនៈ ពូមានដែលធ្លាប់និយាយរឿងរ៉ាវដែលពូជួបប្រទះនៅក្នុងគុក ឬក្នុងបីឆ្នាំអីអញ្ចឹង ពូមានដែលនិយាយប្រាប់អ្នកភូមិ ឬក៏កូនចៅតូចតាច មួយអីមានធ្លាប់និយាយទេ?

ខាៈ ធ្លាប់ៗ ។

គឿនៈ ហេតុអី បានជាពូ ចង់អោយអ្នកភូមិអ្នកអី ដឹង?

ខាៈ អោយវា ចងចាំ ជំនាន់ក្រោយ ។

គឿនៈ ចងចាំថាម៉េច?

ខាៈ ចងចាំកុំថាអោយកូនចៅខាងក្រោយកើតនឹងរឿងអាស្រូវអញ្ចឹងទៀត ។

គឿនៈ វាមានផលលំបាកយ៉ាងម៉េចខ្លះ?

ខាៈ ផលលំបាកដោយសារវេទនារងទុក្ខដោយសារការឈឺចាប់ គេប្រើដោយកំហឹងឈឺចាប់ហ្នឹង ការជិះជាន់ហ្នឹង ។

គឿនៈ ហើយចុះពូយល់ថារឿងរ៉ាវដែលពូជួបប្រទះកាលពីសម័យខ្មែរក្រហមហ្នឹង គួរតែប្រាប់ក្មេងៗជំនាន់ក្រោយអោយបានដឹងដែរឬអត់?

ខាៈ គួរ ។

គឿនៈ ហេតុអីបានជាយើងគួរតែប្រាប់?

ខាៈ គួរតែចងចាំ ដូចវាសម័យអីធ្លែអអញ្ចឹង ។

គឿនៈ កុំអោយកើតមានម្តងទៀត?

ខាៈ ហ្នឹងហើយ ។

គឿនៈ ហើយចុះបើសិនគួរតែប្រាប់ គួរតែប្រាប់តាមវិធីសាស្រ្តបែបណា ដើម្បីអោយក្មេងៗៗទាំងអស់ ជំនាន់ក្រោយទាំងអស់ហ្នឹងបានដឹង?

ខាៈ តាមរបៀបខ្ញុំ តាមទូរទស្សន៍ តាមខ្សែភាពយន្ត ។

គឿនៈ អូ តាមជាខ្សែភាពយន្តផ្សព្វផ្សាយ តាមទូរទស្សន៍តាមអីអញ្ចឹងទៅ?

ខាៈ ហ្នឹងហើយ ។

គៀនៈ ហើយចុះពូចង់អោយមានដូចជាសម័យខ្មែរក្រហមហ្នឹង ប្រវត្តិតាំងពីសម័យខ្មែរក្រហមហ្នឹង ចងក្រងជាឯកសារ អោយក្មេងៗៗជំនាន់ក្រោយរៀននៅក្នុងកម្មវិធីសិក្សា ពូចង់អោយមានអញ្ចឹងទេ?

ខាៈ អោយមានៗ

គៀនៈ ចង់អោយមានអញ្ចឹងដែរ?

ខាៈ បាទៗ

គៀនៈ ហេតុអីបានជាពូចង់អោយគេសិក្សាពីប្រវត្តិខ្មែរក្រហមហ្នឹង?

ខាៈ អោយវាចងចាំសម័យខ្មែរក្រហមហ្នឹង កុំអោយវា កើតឡើងឡើងវិញៗ

គៀនៈ ហើយចុះពូយល់ថាក្មេងៗៗ វាដូចជាផ្ទាំងសំពត់សអញ្ចឹងវារៀន អោយរៀនដឹងពីប្រវត្តិខ្មែរក្រហមអញ្ចឹងវាអាច យល់ថាវាអាចធ្វើតាមខ្មែរក្រហម ឬក៏វាជៀសវាងកុំអោយធ្វើតាមខ្មែរក្រហម?

ខាៈ អោយវាជៀសវាងៗ

គៀនៈ ពូយល់ថាវាអាចធ្វើតាមរឺក៏ជៀសវាង?

ខាៈ អាត្រង់ហ្នឹងខ្ញុំអត់យល់ដែរ មិនដឹងយ៉ាងម៉េច ខ្ញុំអត់ហ៊ានថាទេអាហ្នឹងៗ

គៀនៈ ពូ អត់ថា អោយវារៀន រៀន ដឹងច្រើនទៅ បន្តិចវាធ្វើតាមខ្មែរក្រហម?

ខាៈ ខ្ញុំខ្លាចអញ្ចឹងដែរៗ

គៀនៈ ហើយចុះពូយល់ថាគួរតែធ្វើយ៉ាងម៉េចទៅ ដើម្បីកុំអោយរបបហ្នឹង វិលមកជាលើកទីពីរវិញបាន?

ខាៈ អត់ដឹងទេ អាហ្នឹងៗ

គៀនៈ តាមគំនិតពូ ដែលគិតសាមញ្ញៗៗអាំ យើងគិតថាគួរតែធ្វើយ៉ាងម៉េចកុំអោយរបបហ្នឹងវិលមកវិញបាន?

ខាៈ ពួតដៃសាមគ្គីគ្នា កសាងប្រទេស ទៅៗ

គៀនៈ អូ កុំអោយរបបហ្នឹង វិលមកវិញបាន ពួតដៃគ្នា កសាងប្រទេសៗ

ខាៈ បាទៗ

គឿនៈ ហើយចុះពូយល់ថា ប្រទេសយើងខាងធ្វើម៉េចទៅ ពួតដៃគ្នា ដើម្បីអោយមានសន្តិភាព មានយុត្តិធម៌ មានការផ្សះផ្សារបង្រួបបង្រួមគ្នា ទៅខាងមុខអា៎ ពូយល់ថាគួរតែធ្វើយ៉ាង ម៉េច?

ខាៈ អាហ្នឹង អត់ចេញទេ និយាយអត់ចេញទេ មិនដឹងនិយាយថា ម៉េចអារឿងពួតដៃគ្នា និយាយអោយមានត្រឹមត្រូវ ។

គឿនៈ អាចថា ធ្វើម៉េចទៅដើម្បីអោយមានសន្តិភាព?

ខាៈ សន្តិភាពយើងត្រូវការពារ សន្តិសុខទៅ ។

គឿនៈ អញ្ចឹងសំនួរខ្ញុំសួរ ដូចជាអស់ហើយ ពូមានអីចង់បន្ថែមលើសពីហ្នឹងទៀត មានចង់អី ផ្ដែ ផ្ដាំទៀតទេពូ?

ខាៈ ផ្ដែផ្ដាំអោយរាជរដ្ឋាភិបាល រៀបចំ ដែង តុលាការ ហ្នឹង អោយបានឆាប់រហ័សទៅ ។

គឿនៈ អញ្ចឹងខ្ញុំអរគុណលោកពូច្រើន ។

ចប់